# គោលការណ៍ណែនាំរបស់ចិនស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវ លើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួល ខុសត្រូវ

សមាគមពាណិជ្ជកម្មចិននាំចេញនាំចូល
លោហៈរ៉ែនិងសារធាតុគីមី

CCCMC

# គោលការណ៍ណែនាំរបស់ចិនស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ

ឯកសារបកប្រែនេះ ស្ថិតក្រោមអនុស្សារណៈយោគយល់គ្នាមួយរវាងអង្គការឌីភីអេ និងCCCMC ក្នុងកិច្ចសហប្រតិបត្តិការផ្សព្វផ្សាយគោលការណ៍ណែនាំរបស់ CCCMC

រក្សាសិទ្ធិដោយ
អង្គការអភិវឌ្ឍ និងភាពជាដៃគូក្នុងសកម្មភាព

# សេចក្តីផ្តើមអំពីគោលការណ៍ទាំងនេះ

គោលបំណងនៃគោលការណ៍ណែនាំរបស់ចិន ស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ គឺដើម្បីផ្តល់ជំនួយសម្រាប់ការប្រតិបត្តិការ និងផ្តល់សេចក្តីលម្អិតដល់ប្រការ ២.៤.៦ នៃ*គោលការណ៍ណែនាំ ស្តីអំពីទំនួលខុសត្រូវចំពោះសង្គម នៅក្នុងការវិនិយោគរ៉ែក្រៅប្រទេស*[1] *របស់ CCCMC* តាមរយៈការផ្តល់ជាសេចក្តីណែនាំ និងគាំទ្រដល់ក្រុមហ៊ុនទាំងឡាយដែលកំពុងប្រតិបត្តិការ និង/ឬ ប្រើប្រាស់ធនធានរ៉ែ និងផលិតលផលបន្ទាប់បន្សំនៃធនធានរ៉ែ និងមានពាក់ព័ន្ធនៅក្នុងដំណាក់កាលណាមួយ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ ដើម្បីកំណត់ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យរបស់ពួកគេក្នុងការចូលរួមដោយផ្ទាល់ ឬដោយប្រយោល ក្នុងការបង្កជម្លោះ ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងហានិភ័យ នៃការប្រព្រឹត្តិខុសក្រមសីលធម៌ធ្ងន់ធ្ងរ ។

*គោលការណ៍ណែនាំរបស់ចិន ស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ ប្រកបដោយទំនួលខុសត្រូវ* [2] បានប្រើប្រាស់*គោលការណ៍ណែនាំ ស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ* និង *សៀវភៅណែនាំលើការពិនិត្យដ៏ត្រឹមត្រូវ ស្តីអំពីខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ ក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងហានិភ័យខ្ពស់របស់ OECD* ជាឯកសារគោល ហើយនឹងគាំទ្រការរួមបញ្ចូល និងផ្សារភ្ជាប់ជាមួយបទដ្ឋាន ច្បាប់ និងគំនិតផ្តួចផ្តើមដទៃទៀតដែលពាក់ព័ន្ធ។ ក្រុមហ៊ុនតម្រូវឱ្យអនុវត្តនិងគោរពតាមច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលមានស្រាប់ជាចាំបាច់។ ការអនុវត្តទៅតាមគោលការណ៍ណែនាំនេះ មិនអាចជំនួសកាតព្វកិច្ចច្បាប់ ឬការអនុវត្តច្បាប់ផ្សេងៗដែលមានបានឡើយ។ គោលការណ៍ណែនាំនេះ ត្រូវបានបោះពុម្ពផ្សាយជាផ្លូវ

[1] *គោលការណ៍ណែនាំរបស់ CCCMC ស្តីពីទំនួលខុសត្រូវចំពោះសង្គម នៅក្នុងការវិនិយោគរ៉ែក្រៅប្រទេស* ដែលត្រូវបានផ្សព្វផ្សាយកាលពីថ្ងៃទី ២៤ តុលា ២០១៤នោះ អំពាវនាវដល់ក្រុមហ៊ុនរ៉ែចិនដែលធ្វើការវិនិយោគ សហការណ៍ និងធ្វើពាណិជ្ជកម្មរ៉ែក្រៅប្រទេសទាំងអស់ ឲ្យ "គោរពទៅតាមគោលការណ៍ណែនាំស្តីអំពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ ក្នុងវដ្តជីវិតនៃគម្រោងវិនិយោគរ៉ែរបស់ខ្លួន" ឲ្យបានខ្ជាប់ខ្ជួន និងពង្រឹង "ទំនួលខុសត្រូវទាំងអស់នៅក្នុងខ្សែចង្វាក់ផលិតកម្មនៃឧស្សាហកម្មនិស្សារណកម្មនេះ" ។ គោលការណ៍ណែនាំរបស់ CCCMC នេះក៏មានបញ្ជាក់អំពីតម្រូវការផ្សេងៗក្នុងការ "ពិនិត្យឲ្យបានត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មដែលផ្អែកលើហានិភ័យ ដើម្បីទប់ស្កាត់ការជាប់ពាក់ព័ន្ធនឹងវត្ថុធាតុណា ដែលផ្តល់ហិរញ្ញប្បទាន ឬបង្កឲ្យមានជម្លោះ" (ប្រការ ២.៤.៦ នៃគោលការណ៍ណែនាំ) ។

[2] CCCMC និង OECD មានទស្សនៈសាមញ្ញរួមគ្នា សម្រាប់ភាពចាំបាច់ក្នុងការសហការបង្កើតគោលការណ៍នេះ។ ដូចនេះហើយ ភាគីទាំងពីរ បានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាមួយ ដើម្បីសហប្រតិបត្តិការក្នុងការរៀបចំតាក់តែងគោលការណ៍ណែនាំនេះ។ ការយោគយល់គ្នានេះ គឺយោងទៅតាមទស្សនៈវិស័យ និងផែនការសកម្មភាព រយៈពេលមធ្យម រវាងចិន និង OECD ក្នុងឆ្នាំ ២០១៥-២០១៦។

ការ ជាភាសាចិន និងភាសាអង់គ្លេស ហើយនឹងបកប្រែជាភាសាផ្សេងៗទៀត។ ឯកសារជាភាសាចិនជាឯកសារដើម។ ប្រសិនបើមានភាពខុសគ្នា ឬភាពលំអៀងនៅក្នុងការបកប្រែ ឯកសារជាភាសាចិនមានអំណាចជាង។

ឯកសារគោលការណ៍នេះ ត្រូវបានរក្សាសិទ្ធិ ក្នុងការពិនិត្យនិងកែតម្រូវ ដើម្បីឲ្យសមស្របទៅតាមការអភិវឌ្ឍនៃប្រតិបត្តិការឧស្សាហកម្មនេះ។

# មាតិកា


១. សារតារ និង ការប្រេឈម ........................................................................................... 6

២. វត្ថុបំណង ............................................................................................................... 8

៣. វិសាលភាពនៃការអនុវត្ត ............................................................................................ 10

៤. ការណែនាំពីជំហានមូលដ្ឋាននៃការពិនិត្យដ៏ត្រឹមត្រូវ ដែលផ្អែកលើហានិភ័យ...................................... 12

៥. ប្រភេទនៃហានិភ័យ ចំពោះការពិនិត្យដ៏ត្រឹមត្រូវ............................................................... 14

៦. សញ្ញាព្រមាន ............................................................................................................ 22

៧. ក្របខ័ណ្ឌ និងដំណើរការនៃការពិនិត្យដ៏ត្រឹមត្រូវ .................................................................... 26

៨. សវនកម្ម លិខិតបញ្ជាក់ និងការត្រួតពិនិត្យ ......................................................................... 32

ឧបសម្ព័ន្ធ ៖ គោលនយោបាយខ្សែចង្វាក់ផលិតកម្មគំរូ....................................................................... 33

# ១. សារតារ និង ការប្រឈម

ប្រតិបត្តិការ និងការធ្វើពាណិជ្ជកម្ម ធនធានធម្មជាតិផ្តល់ផលយ៉ាងមានសក្តានុពលភាពដល់ចំនួលការរីកចម្រើននិងវិបុលភាព និងជម្រុញឲ្យទំនាក់ទំនងប្រកបដោយអត្ថប្រយោជន៍ទៅវិញទៅមក រវាងសហគមន៍និងក្រុមហ៊ុន ជាលក្ខណៈសហប្រតិបត្តិការណ៍ និងជាបុគ្គល។ តែផ្ទុយទៅវិញ ក្នុងប្រទេសមួយចំនួន និងនៅតំបន់ខ្លះជាពិសេសក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ ប្រតិបត្តិការ និងការធ្វើពាណិជ្ជកម្មលើធនធានធម្មជាតិ ញុាំងឲ្យមានជម្លោះ ដោយអំពើហិង្សា និងការរំលោភសិទ្ធិមនុស្ស។ ឧទាហរណ៍ នៅប្រទេសមួយចំនួន ការកេងប្រវ័ញ្ច និងពាណិជ្ជកម្មលើធនធានធម្មជាតិ ដូចជាពេជ្រ ឈើ និងធនធានរ៉ែបានធ្វើឲ្យមានសង្គ្រាមស៊ីវិល និងជម្លោះហិង្សា។ សារជាតុរ៉ែដែលគេហៅកាត់ថា "3TG" មានដូចជា ស័ង្កសី ទង់ដែង តាន់តាលូមនិងមាស ជាធនធានរ៉ែដែលទាក់ទាញការចាប់អារម្មណ៍ខ្លាំង ដោយសារតែកើតមានជម្លោះជាបន្តបន្ទាប់ នាពេលថ្មីៗនេះ។

រយៈពេលមួយទសវត្សរ៍កន្លងមកនេះ សហគមន៍អន្តរជាតិ បានព្យាយាមរកឲ្យឃើញនូវទំនាក់ទំនងរវាងធុរកិច្ច និងការរំលោភសិទ្ធិមនុស្ស ។ សហគមន៍អន្តរជាតិ បានឆ្លើយតបទៅនឹងបញ្ហាតាមរយៈវិធានការផ្សេងៗគ្នា ដូចជាដំណោះស្រាយរបស់អង្គការសហប្រជាជាតិ ទៅដល់វិធានការ Kimberley Process និងជាចុងក្រោយបង្កើតបទដ្ឋាន ច្បាប់ និងបទប្បញ្ញត្តិជាសកល ក្នុងគោលបំណងដើម្បីផ្តាច់ទំនាក់ទំនងរវាងសារជាតុរ៉ែ និងជម្លោះប្រដាប់អាវុធ ព្រមទាំងជាមួយនឹងការរំលោភសិទ្ធិមនុស្ស។ ក្នុងឆ្នាំ២០១១ ក្រុមប្រឹក្សាសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ បានអនុម័តជាឯកច្ឆ័ន្ទលើ "គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ" ដែលជាក្របខណ្ឌនៃការទទួលខុសត្រូវលើសិទ្ធិមនុស្សរបស់សាជីវកម្មលើកដំបូង ដែលត្រូវបានគាំទ្រជាសកល។

ការទទួលខុសត្រូវចម្បងរបស់ក្រុមហ៊ុន គឺដើម្បីធានាឲ្យបានថាពួកគេមិនបង្កបញ្ហា និងចូលរួមចំណែកឬក៏ទទួលបានផលប្រយោជន៍ ពីការរំលោភសិទ្ធិមនុស្ស និងជម្លោះប្រដាប់អាវុធ ដោយចេតនា ឬអ-ចេតនា និងគោរពសិទ្ធិមនុស្សរបស់អ្នកទាំងអស់ ដែលអាចទទួលរងផលប៉ះពាល់ពីសកម្មភាពធុរកិច្ចរបស់ពួកគេ។ ដូចនេះហើយ ក្រុមហ៊ុនដែលមានទំនួលខុសត្រូវ ត្រូវធ្វើការពិនិត្យដ៏ត្រឹមត្រូវជាប្រចាំ និងទូលំទូលាយ ទៅលើសកម្មភាពធុរកិច្ចទាំងអស់របស់ពួកគេ រួមបញ្ចូលទាំងហានិភ័យទាំងអស់ដែលអាចមាននៅក្នុងខ្សែចង្វាក់ផលិតកម្ម ដែលពួកគេទាញយកប្រភពពីធនធានធម្មជាតិ។ ក្របខណ្ឌ

ដែលទទួលស្គាល់ជាអន្តរជាតិក្នុងការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្ម គឺ"សៀវភៅណែនាំរបស់ OECD ស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវ លើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួលខុសត្រូវក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់"(ដែលហៅកាត់ថា "សៀវភៅណែនាំលើការពិនិត្យដ៏ត្រឹមត្រូវរបស់ OECD") ដែលបានប្រើប្រាស់ជាមូលដ្ឋាន សម្រាប់កម្មវិធីឧស្សាហកម្មភាគច្រើន ស្តីអំពីខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ ប្រកបដោយទំនួលខុសត្រូវ[3] ក្នុងប្រទេសនានា។

---

[3] សហគមអន្តរជាតិ បានរៀបចំការណែនាំស្តីពីការពិនិត្យដ៏ត្រឹមត្រូវសម្រាប់ក្រុមហ៊ុនផ្សេងៗដែលកំពុងទទួលប្រភពធនធានរ៉ែ ពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះនិងមានហានិភ័យខ្ពស់ តាមរយៈដំណើរការពហុភាគី ដែលរាប់បញ្ចូលសន្និសិទអន្តរជាតិលើតំបន់ The Great Lakes Region (ICGLR) អង្គការសម្រាប់កិច្ចសហប្រតិបត្តិការលើសេដ្ឋកិច្ច និងការអភិវឌ្ឍ (OECD) និងក្រុមអ្នកជំនាញរបស់អង្គការសហប្រជាជាតិ។ ក្រុមប្រឹក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិ (UNSC) សេចក្តីសម្រេច ឆ្នាំ១៩៥២ ទទួលយកអនុសាសន៍នៃការពិនិត្យដ៏ត្រឹមត្រូវ ដែលមាននៅក្នុងរបាយការណ៍ចុងក្រោយរបស់អ្នកជំនាញរបស់អង្គការសហប្រជាជាតិ ដែលឆ្លើយតបទៅនឹងភ័ស្តុតាងរយៈពេលវែងនៃទំនាក់ទំនងរវាងជម្លោះប្រដាប់អាវុធ និងការរំលោភសិទ្ធិមនុស្ស នៅភាគខាងកើតនៃសាធារណរដ្ឋប្រជាធិប-តេយ្យកុងហ្គោ និងពាណិជ្ជកម្មស័ង្កសី តាន់តាលូម ទង់ដែងនិងមាស។ គោលការណ៍ណែនាំស្តីពីការពិនិត្យដ៏ត្រឹមត្រូវរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងOECD ត្រូវបានរចនាឡើងដើម្បីឲ្យមានលក្ខណៈស្របគ្នា។

# ២. វត្ថុបំណង

វត្ថុបំណងនៃគោលការណ៍ណែនាំរបស់ចិន ស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផ្គត់ផ្គង់ធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ(ដែលហៅកាត់ថា "**គោលការណ៍ណែនាំ**") គឺដើម្បីផ្តល់ជំនួយប្រតិបត្តិការ និងផ្តល់សេចក្តីលម្អិតដល់ប្រការ ២.៤.៦ នៃគោលការណ៍ណែនាំរបស់ចិនស្តីពីទំនួលខុសត្រូវចំពោះសង្គម នៅក្នុងការវិនិយោគរ៉ែក្រៅប្រទេស(ដែលហៅកាត់ថា"**គោលការណ៍ណែនាំរបស់ចិនស្តីពីទំនួលខុសត្រូវ ក្នុងការវិនិយោគរ៉ែ**)[4] ដោយធ្វើការផ្តល់នូវសេចក្តីណែនាំ ទៅដល់ក្រុមហ៊ុនចិនទាំងអស់ដែលធ្វើប្រតិបត្តិការ និងកំពុងប្រើប្រាស់ធនធានរ៉ែ និងផលិតផលបន្ទាប់បន្សំធនធានរ៉ែ ហើយពាក់ព័ន្ធក្នុងដំណាក់កាលណាមួយនៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ ដើម្បីកំណត់ ទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃការរួមចំណែកបង្កជម្លោះ ការរំលោភសិទ្ធិមនុស្ស និងហានិភ័យនៃការប្រព្រឹត្តខុសក្រមសីលធម៌ធ្ងន់ធ្ងរ ព្រមទាំងដើម្បីពិនិត្យមើលគោលការណ៍ណែនាំ ស្តីអំពីធុរកិច្ចនិងសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិ ក្នុងអំឡុងពេលនៃវដ្តជីវិតនៃគម្រោងវិនិយោគរ៉ែ ។

តាមរយៈនេះហើយ **គោលការណ៍ណែនាំ**នឹង ជួយគាំទ្រក្រុមហ៊ុនទាំងឡាយឲ្យសម្រេចបាននូវអនុលោមភាពតាមច្បាប់និងបទប្បញ្ញត្តិនៃពាណិជ្ជកម្ម ដែលបានអនុម័ត ឬស្ថិតនៅក្នុងដំណើរការនៃការអនុម័តច្បាប់ ដែលតម្រូវឱ្យមានការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែនេះ និង/ឬ សម្រេចបាននូវការអនុលោមទៅតាមគំនិតផ្តួចផ្តើមឧស្សាហកម្ម ដែលធ្វើឱ្យកាន់តែប្រសើរឡើងនូវការឈានចូលទីផ្សារ [5] ។

---

[4] ប្រការ ២.៤.៦ ទាមទារក្រុមហ៊ុនទាំងឡាយឱ្យ "ធ្វើការពិនិត្យដ៏ត្រឹមត្រូវនៅក្នុងខ្សែចង្វាក់ផលិតកម្មដែលផ្អែកលើហានិភ័យ ដើម្បីទប់ស្កាត់ការជាប់ពាក់ព័ន្ធនឹងវត្ថុជាតុណា ដែលបណ្តាលឲ្យមានជម្លោះ"។ អនុប្រការនៃប្រការនេះទាមទារបន្ថែមឲ្យ៖ "ក. ធ្វើការវាយតម្លៃមួយដើម្បីកំណត់ថា តើគម្រោងវិនិយោគរ៉ែ ដែលការធ្វើពាណិជ្ជកម្មរ៉ែទាំងនេះ មានប្រភពមកពី ឬបណ្តាញផ្លូវដឹកជញ្ជូន នៅទីតាំងនៅក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ ឬ/និង មានហានិភ័យខ្ពស់ដែរឬទេ? ខ. អនុវត្តតាមវិធានការនៃការពិនិត្យដ៏ត្រឹមត្រូវដែលមានស្រាប់នៅក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងហានិភ័យខ្ពស់។ វិធានការទាំងឡាយ ត្រូវពិនិត្យដោយភាគីទី៣ និងផ្សព្វផ្សាយជាសាធារណៈ និង គ. ពេលធ្វើប្រតិបត្តិការក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ ឬ/និងមានហានិភ័យខ្ពស់ ត្រូវចាត់វិធានការដើម្បីត្រួតពិនិត្យលើទំនាក់ទំនងធុរកិច្ច ប្រតិបត្តិការ និងលំហូនៃមូលនិធិនិងធនធានទាំងឡាយ ហើយនិងចៀសវាងការធ្វើពាណិជ្ជកម្មរ៉ែដែលមានជម្លោះ។

[5] ឧទាហរណ៍៖ តម្រូវការផ្លូវច្បាប់នៃខ្សែចង្វាក់ផលិតកម្មប្រកបដោយទំនួលខុសត្រូវ ត្រូវបានដាក់បញ្ចូលទៅក្នុង*ផ្នែក ១៥០២ នៃច្បាប់កំណែទំរង់ Dodd-FrankWall Street និងការការពារអ្នកប្រើប្រាស់* និងក្នុងច្បាប់ក្នុងស្រុកនៃសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ប្រទេសរវ៉ាន់ដា និង ប្រទេសប៊ូរុនឌី។ មិនត្រឹមតែប៉ុណ្ណោះ ប្រទេសជាសមាជិក របស់សន្និសិទអន្តរជាតិនៃតំបន់ The Great Lakes (ICGLR) បានបង្កើត*គំនិតផ្តួចផ្តើមប្រចាំតំបន់ ប្រឆាំងនឹងការបំផ្លាញនិងការកេងប្រវ័ញ្ចដោយខុសច្បាប់ទៅលើធនធានធម្មជាតិ*

អត្ថប្រយោជន៍ដែលរំពឹងទុកផ្សេងទៀត សម្រាប់ក្រុមហ៊ុនប្រតិបត្តិការរួមមាន៖

1. បង្កើនសមត្ថភាពដើម្បីបំពេញតាមការរំពឹងទុកនៃអតិថិជននិង ទីផ្សារសម្រាប់ប្រតិបត្តិការធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ
2. ពង្រឹងការយល់ដឹង ការប្រមូលព័ត៌មាន និងការគ្រប់គ្រងលើខ្សែចង្វាក់ផលិតកម្ម និងយុទ្ធ-សាស្ត្រកំណត់ប្រភពធនធានរ៉ែ ដើម្បីជម្រុញឲ្យមានការសម្រេចចិត្តដែលមានលក្ខណៈជាយុទ្ធសាស្ត្រ និងមានព័ត៌មានគ្រប់គ្រាន់
3. ធ្វើឱ្យប្រសើរឡើងនូវកេរ្តិ៍ឈ្មោះរបស់ក្រុមហ៊ុនដែលបានចូលរួមនិងក្រុមហ៊ុនឧស្សាហកម្មចិន
4. កាត់បន្ថយការរំខានក្នុងការផ្គត់ផ្គង់ដែលបង្កឡើងដោយជម្លោះ និង អភិបាលកិច្ចទន់ខ្សោយ
5. ផ្តល់ជូននូវការណែនាំដល់ក្រុមហ៊ុន ដែលចង់អនុវត្តការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិត-កម្ម ក្នុងធនធានធម្មជាតិដទៃទៀតក្រៅពីធនធានរ៉ែ ។

---

(RINR) និងយន្តការនៃលិខិតបញ្ជាក់ប្រចាំតំបន់ (RCM) គឺគម្រោងបញ្ជាក់ និងតាមដានធនធានរ៉ែរបស់ ICGLR។ គំនិតផ្តួចផ្តើមឧស្សាហកម្មនានា រួមមាន*កម្មវិធីអ្នករំលាយរ៉ែដោយគ្មានជម្លោះ*ដែលត្រូវបានអភិវឌ្ឍដោយ សម្ព័ន្ធអ្នកឧស្សាហកម្មអេឡិចត្រូនិច(EICC) និងគំនិតផ្តួចផ្តើមឲ្យមាននិរន្តរភាពអេឡិចត្រូនិចជាសកល (GeSI) បទដ្ឋានរ៉ែមាសដែលគ្មានជម្លោះសំរាប់ក្រុមប្រឹក្សារ៉ែមាសពិភពលោក (2012) សេចក្តីណែនាំនៃរ៉ែមាសដែលប្រកបដោយទំនួលខុសត្រូវ របស់សមាគមទីផ្សារមាសជុំនៃទីក្រុងឡុង (2012) លិខិតបញ្ជាក់ដំណើររក្សាភស្តុតាងរបស់ក្រុមប្រឹក្សាគ្រឿងអលង្ការប្រកបដោយការទទួលខុសត្រូវ (2012) និង បទដ្ឋាន Fairtrade និង Fairmined សំរាប់រ៉ែមាសដែលបានមកពីការរុករករ៉ែដោយដៃ និងដោយសិប្បកម្មខ្នាតតូចរបស់សម្ព័ន្ធរុករករ៉ែប្រកបដោយទំនួលខុសត្រូវ/ អង្គការសំរាប់ស្លាកសញ្ញា Fairtrade អន្តរជាតិ (2012) ជាងនេះទៅទៀត ការអនុវត្តតាម គោលការណ៍ណែនាំ ពង្រឹងការអនុលោមទៅនឹងអនុសាសន៍នៃក្រុមការងារសកម្មភាពហិរញ្ញវត្ថុ (FATF) ដើម្បីប្រឆាំងនឹងសកម្មភាពលាងលុយ ហើយនិងការប្រឆាំងនិងការផ្តល់ហិរញ្ញប្បទានទៅពួកភេរវជន (AML/CFT) ដែលក្នុងនោះ ប្រទេសចិនជាសមាជិក ព្រមទាំងជាមួយនឹងស្តង់ដារដែលបានស្ថិតនៅក្រោមគំនិតផ្តួចផ្តើមធ្វើឲ្យមានតម្លាភាពនៅក្នុងឧស្សាហកម្មនិស្សារណកម្ម (EITI)។ ការធ្វើសេចក្តីរាយការណ៍លើការចំណាយអោយរដ្ឋាភិបាលសម្រាប់ប្រតិបត្តិការរ៉ែនេះ គឺជាតម្រូវការចាំបាច់នៅក្នុងប្រទេសចំនួន ៤៨ ដែលកំពុងប្រតិបត្តិតាម EITI ។

# ៣. វិសាលភាពនៃការអនុវត្ត

គោលការណ៍ណែនាំនេះត្រូវអនុវត្ត ចំពោះក្រុមហ៊ុនចិនទាំងអស់ ដែលកំពុងប្រតិបត្តិការ ធ្វើពាណិជ្ជកម្ម ចម្រាញ់ ដឹកជញ្ជូន និង/ឬ កំពុងតែប្រើប្រាស់ធនធានរ៉ែហើយនិងផលិតផលផ្សេងៗនៃធនធានរ៉ែនោះ និងពាក់ព័ន្ធនៅក្នុងដំណាក់កាលណាមួយ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែនិង ផលិតផលផ្សេងៗនៃធនធានរ៉ែទាំងនោះ។ និយមន័យនេះ គ្របដណ្តប់ទៅលើគ្រប់ក្រុមហ៊ុនចិនដែលធ្វើប្រតិបត្តិការផ្នែកអាប់ស្ទ្រីម (upstream) ដូចជាការស្វែងរុករក ការទាញយក ការធ្វើពាណិជ្ជកម្ម ការដឹកជញ្ជូន និងការស្តុកទុក រហូតដល់ដំណាក់កាលចម្រាញ់ ដែលរាប់បញ្ចូលទាំងការចម្រាញ់ និង\ឬ ការរំលាយ ព្រមទាំងប្រតិបត្តិការផ្នែកដោនស្ទ្រីម (downstream) ដែលអាចមានភាពពាក់ព័ន្ធទៅនឹងការប្រើប្រាស់ធនធានរ៉ែ និងផលិតផលផ្សេងៗនៃធនធានរ៉ែទាំងនោះ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ (ឧទាហរណ៍ដូចជា៖ គ្រឿងអេឡិចត្រូនិច ឧបករណ៍អគ្គិសនី ឧបករណ៍នានា គ្រឿងអលង្ការ ឧបករណ៍ទំនាក់ទំនង -ល-)។ ពាក្យថា "ក្រុមហ៊ុនចិន" ក្នុងន័យនេះ សំដៅរាល់ស្ថាប័ននីតិបុគ្គលស្របច្បាប់ទាំងឡាយណា(ដើម្បីផលចំណេញ) បានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងប្រទេសចិន ឬនៅក្រៅប្រទេស (រាប់បញ្ចូលទាំងក្រុមហ៊ុនបុត្រសម្ព័ន្ធ)ដែលមានកម្មសិទ្ធិពេញលេញ ឬមានភាគហ៊ុនច្រើន ឬគ្រប់គ្រង ដោយនីតិបុគ្គល និងរូបវន្តបុគ្គលជាជនជាតិចិន ។

ធនធានរ៉ែ នៅក្នុងគោលការណ៍ណែនាំនេះ សំដៅលើគ្រប់ធនធានរ៉ែទាំងអស់និងផលិតផលផ្សេងៗនៃធនធានរ៉ែទាំងនោះ (ឧ. សារជាតុរ៉ែ កំហាប់រ៉ែ លោហៈ ផលិតផលផ្សំ ផលិតផលបន្ទាប់បន្សំ)។ ក៏ប៉ុន្តែជាការចាប់ផ្តើម CCCMC នឹងផ្តល់អាទិភាពលើការផ្សព្វផ្សាយនិតិវិធីសវនកម្ម និងឯកសារបន្ថែមដែលរៀបរាប់អំពីខ្សែចង្វាក់ផលិតកម្មធនធានរ៉ែហើយនិងផលិតផលផ្សេងៗនៃធនធានរ៉ែទាំងនោះ ដូចខាងក្រោម ៖

| | |
|---|---|
| មាស | លោហៈធាតុ(រាប់ទាំង លោហធាតុក្លាយ) រ៉ែ និងកំហាប់រ៉ែដែលមានមាស |
| សំណ | លោហៈធាតុ(រាប់ទាំង លោហធាតុក្លាយ) រ៉ែ និងកំហាប់រ៉ែដែល មានសំណប៉ាហាំង (រ៉ែ Cassiterite និង រ៉ែសំណប៉ាហាំងផ្សេងៗទៀត) |
| ទង់ដែង | លោហៈធាតុ (រាប់ទាំង លោហធាតុក្លាយ) រ៉ែ និងកំហាប់រ៉ែដែលមានទង់ ដែង (Wolframite និង រ៉ែទង់ដែងដទៃទៀត) |
| តាន់តាលូម | លោហៈធាតុ (រាប់ទាំង លោហធាតុក្លាយ) រ៉ែ និងកំហាប់រ៉ែដែលមាន Niobium ឬ Tantalum (Coltan, Columbite, Tantalite, Niobite, Pyrochlorite និង ប្រភេទរ៉ែ Nb-Ta ផ្សេងទៀត) |

វិសាលភាពនៃការពិនិត្យដ៏ត្រឹមត្រូវដែលសមស្រប នឹងពឹងផ្អែកលើស្ថានភាពជាក់ស្តែងនិងទទួលឥទ្ធិពលដោយសារកត្តាផ្សេងៗដូចជា ទំហំសហគ្រាស[6] វិស័យ និងលក្ខណៈនៃផលិតផល និងសេវាកម្មដែលពាក់ព័ន្ធ ក៏ដូចជាការរួមចំណែករបស់ក្រុមហ៊ុន នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ និងភាពកើតឡើងជាទូទៅនៃហានិភ័យ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ។ គោលការណ៍ណែនាំនេះដាក់បញ្ចូលនិតិវិធីសវនកម្មដោយផ្អែកលើធនធានរ៉ែជាក់លាក់ និងឯកសារបន្ថែម នៅក្នុងឧបសម្ព័ន្ធដែលរៀបរាប់លម្អិតនូវការណែនាំសម្រាប់ក្រុមហ៊ុន ថាតើធ្វើយ៉ាងណាដើម្បីសម្រេចបាននូវការពិនិត្យដ៏ត្រឹមត្រូវទៅតាមវិស័យនីមួយៗ។

ក្រុមហ៊ុនដែលមានប្រតិបត្តិការនៅក្នុងខ្សែចង្វាក់ផលិតកម្មនៃធនធានធម្មជាតិផ្សេងទៀត ក៏ត្រូវបានលើកទឹកចិត្តឲ្យប្រើប្រាស់គោលការណ៍ណែនាំនេះ ជាឯកសារយោងផងដែរ។

[6] ក្រុមហ៊ុនដែលមានទំហំតូច មិនត្រូវបានលើកលែងពីការអនុវត្តជំហានទាំងអស់ ដែលមានក្នុងគោលការណ៍ណែនាំនោះទេ ក៏ប៉ុន្តែអាចអនុវត្តតាមដំណើរការដែលសមស្របទៅនឹងទំហំក្រុមហ៊ុនរបស់ពួកគេ។

# ៤. ការណែនាំពីជំហានមូលដ្ឋាននៃការពិនិត្យដ៏ត្រឹមត្រូវ[7] ដែលផ្អែកលើហានិភ័យ

**គោលការណ៍ណែនាំនេះ** បង្ហាញពីគំរូជាមូលដ្ឋាន៥ជំហាន សម្រាប់អនុវត្តការពិនិត្យដ៏ត្រឹមត្រូវនៅក្នុងខ្សែចង្វាក់ផលិតកម្មដែលផ្អែកលើហានិភ័យ។ យោងតាមគោលការណ៍ណែនាំរបស់អង្គការសហប្រជា-ជាតិ ការត្រួតពិនិត្យដ៏ត្រឹមត្រូវ របស់ក្រុមហ៊ុនក្នុងការដោះស្រាយផលប៉ះពាល់សិទ្ធិមនុស្សអវិជ្ជមានត្រូវរួមបញ្ចូល "ការវាយតម្លៃលើផលប៉ះពាល់សិទ្ធិមនុស្សជាសក្តានុពល និងជាក់ស្តែង ការរួមបញ្ចូលនិងចំណាត់ការទៅតាមការរកឃើញ ធ្វើការតាមដានលើការឆ្លើយតប ហើយនិងធ្វើការទំនាក់ទំនងពីវិធីដោះស្រាយផលប៉ះពាល់ទាំងនោះ"[8] ។ OECD ឲ្យនិយមន័យលើការពិនិត្យដ៏ត្រឹមត្រូវថាគឺ "ដំណើរការជាប្រចាំ យ៉ាងសកម្មនិងដោយមានការឆ្លើយតប សម្រាប់ឲ្យក្រុមហ៊ុនទាំងឡាយអាចធានាបានថាពួកគេគោរពសិទ្ធិមនុស្ស និងមិនបង្កឲ្យមានជម្លោះណាមួយ។ ការពិនិត្យដ៏ត្រឹមត្រូវ អាចជួយក្រុមហ៊ុនដើម្បីជានាបានថាពួកគេសិក្សាពីច្បាប់អន្តរជាតិ និងគោរពតាមច្បាប់ជាតិ រាប់បញ្ចូលទាំងការគ្រប់គ្រងពាណិជ្ជកម្មខុសច្បាប់លើធនធានរ៉ែ និងការដាក់ទណ្ឌកម្ម របស់អង្គការសហប្រជាជាតិ។ ការពិនិត្យដ៏ត្រឹមត្រូវដែលផ្អែកលើហានិភ័យ សំដៅលើជំហានទាំងឡាយណា ដែលក្រុមហ៊ុនគួរតែអនុវត្ត ដើម្បីកំណត់និងដោះស្រាយហានិភ័យជាក់ស្តែង ឬជាសក្តានុពល ក្នុងគោលបំណងទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែល កើតអាចចេញពីសកម្មភាពរបស់ពួកគេ និងការសម្រេចចិត្តក្នុងការទទួលប្រភពធនធានរ៉ែ។"[9]

[7] នៅក្នុងគោលការណ៍ណែនាំនេះ ពាក្យ "Due Diligence" ត្រូវបានបកប្រែជា "尽责" និង "尽责管理"។ នៅពេលខ្លះ ពាក្យនេះត្រូវបានបកប្រែ "尽职调查" រួមបញ្ចូលទាំងការបកប្រែផ្លូវការជាភាសាចិននៃឯកសារ "OECD Due Diligence Guidance for Responsible Supply Chains of Minerals from Conflict-Affected and High-Risk Areas"។ ប៉ុន្តែ "Due Diligence" ត្រូវបានបកប្រែជា "尽责" ឬ "尽责管理" សម្រាប់ការបកប្រែផ្លូវការជាភាសាចិននៃឯកសារ "United Nations Guiding Principles on Business and Human Rights" ដែលបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិ។ គោលការណ៍ណែនាំនេះ និងឯកសារពាក់ព័ន្ធនឹងប្រើប្រាស់ការបកប្រែជាផ្លូវការពីឯកសារអង្គការសហប្រជាជាតិ។

[8] អង្គការសហប្រជាជាតិ (២០១១)៖ គោលការណ៍ណែនាំស្តីពីធុរកិច្ច និងសិទ្ធិមនុស្ស៖ ការអនុវត្តក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពី "ការការពារ ការគោរព និងដំណោះស្រាយ"ចំនុច II.B.17

[9] OECD (2013)៖ សៀវភៅណែនាំ ស្តីអំពីការពិនិត្យដ៏ត្រឹមត្រូវ លើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែប្រកបដោយទំនួលខុសត្រូវ ក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ (ទំព័រទី ១៣)

ដោយសារបរិយាកាសនៃប្រតិបត្តិការអាចមានលក្ខណៈស្មុគស្មាញ រួមបញ្ចូលទាំងបរិយាកាស នៃតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ ដែលលក្ខខ័ណ្ឌអាចកើនឡើងនិងអាចចុះថយយ៉ាងឆាប់រហ័ស ការពិនិត្យដ៏ត្រឹមត្រូវ ត្រូវបានយល់ឃើញថាជាដំណើការជាប្រចាំ នៅក្នុងខ្សែចង្វាក់ផលិតកម្ម ដែលក្រុមហ៊ុនអនុវត្តជំហានសមស្រប និងធ្វើការប្រឹងប្រែងប្រកបដោយសុឆន្ទៈ ដើម្បីកំណត់និងឆ្លើយតបទៅនឹងហានិភ័យជាសក្តានុពល ក្នុងការបង្កឲ្យមានជម្លោះ ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និងការប្រព្រឹត្តខុសក្រមសីលធម៌ធ្ងន់ធ្ងរ។

គ្រប់ក្រុមហ៊ុន ទាំងអស់ដែលស្ថិតក្រោមនិយមន័យនៃមាតិកាចំណុចទី៣ នៃគោលការណ៍ណែនាំនេះត្រូវសម្រេចឲ្យបាននូវជំហានទាំង៥ សម្រាប់ក្របខណ្ឌនៃការពិនិត្យដ៏ត្រឹមត្រូវ នៅក្នុងខ្សែចង្វាក់ផលិតកម្មដែលផ្អែកលើហានិភ័យ ដែលត្រូវបានបង្ហាញនៅក្នុងគោលការណ៍ណែនាំនេះ។

ជំហានទាំង ៥នេះមាន ៖

| | |
|---|---|
| **ជំហានទី ១** | បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យរបស់ក្រុមហ៊ុនដែលមានលក្ខណៈរឹងមាំ |
| **ជំហានទី ២** | កំណត់ និងវាយតម្លៃហានិភ័យក្នុងខ្សែចង្វាក់ផលិតកម្ម |
| **ជំហានទី ៣** | បង្កើត និងអនុវត្តយុទ្ធសាស្ត្រមួយដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលបានកំណត់ |
| **ជំហានទី ៤** | ធ្វើសវនកម្មឯករាជ្យដោយភាគីទីបី ទៅលើចំណុចរាំងស្ទះ ដែលត្រូវបានកំណត់រួចនៅក្នុងខ្សែចង្វាក់ផលិតកម្ម (ដូចដែលបានបង្ហាញនៅក្នុងនីតិវិធីសវនកម្ម) |
| **ជំហានទី ៥** | រៀបចំរបាយការណ៍អំពីដំណើការ និងលទ្ធផលនៃការគ្រប់គ្រងហានិភ័យ នៅក្នុងខ្សែចង្វាក់ផលិតកម្ម |

ការណែនាំលម្អិតក្នុងការអនុវត្តជំហានទាំង៥ នៃការពិនិត្យដ៏ត្រឹមត្រូវលើខ្សែចង្វាក់ផលិតកម្មដែលផ្អែកលើហានិភ័យត្រូវបានបង្ហាញនៅក្នុងមាតិកាចំណុចទី៧ ហើយនឹងត្រូវពន្យល់ជាក់លាក់បន្ថែម នៅក្នុងនិតិវិធីសវនកម្ម ទៅលើធនធានជាក់លាក់ និងឯកសារបន្ថែមដែលមាននៅក្នុងឧបសម្ព័ន្ធនៃគោល-ការណ៍ណែនាំនេះ ។

# ៥. ប្រភេទនៃហានិភ័យ ចំពោះការពិនិត្យដ៏ត្រឹមត្រូវ

ការពិនិត្យដ៏ត្រឹមត្រូវដែលផ្អែកលើហានិភ័យ គឺជាវិធីសាស្ត្រដែលអាចបត់បែនបាន មានន័យថាកំរិតនៃតម្រូវការការពិនិត្យដ៏ត្រឹមត្រូវរបស់ក្រុមហ៊ុន គឺសមាមាត្រទៅនឹងហានិភ័យដែលពួកគេជួបប្រទះ។ ហានិភ័យដែលពាក់ព័ន្ធនឹងគោលការណ៍ណែនាំនេះ ត្រូវបានរៀបរាប់ក្នុងផ្នែកនេះ។ ប្រសិនបើយោងទៅតាមការពិនិត្យដ៏ត្រឹមត្រូវរបស់ពួកគេ ក្រុមហ៊ុនមួយរកឃើញហានិភ័យមួយក្នុងចំណោមហានិភ័យដែលមាននៅក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ ឬតាមរយៈការកំណត់ប្រភពធនធានរ៉ែ ពួកគេត្រូវអនុវត្តឲ្យបាននូវការពិនិត្យដ៏ត្រឹមត្រូវ "ដែលប្រសើរ"។ ការពិនិត្យដ៏ត្រឹមត្រូវ "ដែលប្រសើរ" បញ្ចូលទាំងការវាយតម្លៃហានិភ័យ និងប្រតិបត្តិការគ្រប់គ្រងដ៏ស៊ីជម្រៅ ដូចមានក្នុងជំហានទី២និងទី៣នៃក្របខណ្ឌនៃជំហានទាំង៥ដែលបានលើកឡើងខាងលើ។

នៅក្នុងគោលការណ៍ណែនាំនេះ មានការកំណត់ប្រភេទហានិភ័យ២ខុសគ្នា គឺហានិភ័យប្រភេទ១ និងហានិភ័យប្រភេទ២។[10] ប្រភេទនៃហានិភ័យទាំងពីរនេះ កើតឡើងពីតម្រូវការដែលបានរៀបរាប់នៅក្នុងគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវលើការវិនិយោគរ៉ែ និងដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ជាពិសេស។

ហានិភ័យប្រភេទទី១ ជាហានិភ័យទាំងឡាយណាដែលនាំឲ្យមានជម្លោះនិងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលអាចកើតចេញពីប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ និងការនាំចេញធនធានរ៉ែ នៅតំបន់ដែលរងប៉ះពាល់ដោយជម្លោះនិងមានហានិភ័យខ្ពស់[11]។ ហានិភ័យប្រភេទទី២ ជាហានិភ័យទាំងឡាយណា ដែលទាក់ទងទៅនឹងការប្រព្រឹត្តខុសធ្ងន់ធ្ងរ ទៅលើបញ្ហាបរិស្ថាន សង្គម និងក្រមសីលធម៌ (បន្ថែមពីលើហានិភ័យប្រភេទទី១)[12] ។

---

[10] ការបែងចែករវាងហានិភ័យប្រភេទទី១ ឬហានិភ័យប្រភេទទី២ មិនមានន័យថាឲ្យអាទិភាពហានិភ័យប្រភេទទី១ ជាងហានិភ័យប្រភេទទី២នោះឡើយ។ ក្រុមហ៊ុន ត្រូវកំណត់ និងចាត់អាទិភាពហានិភ័យ មិនមែនដោយផ្អែកទៅលើប្រភេទនៃហានិភ័យឡើយ ប៉ុន្តែផ្អែកទៅលើកម្រិតធ្ងន់ធ្ងរ និងភាពដែលអាចកើតមាននៃផលប៉ះពាល់ ដល់ភាគីពាក់ព័ន្ធដែលអាចរងប៉ះពាល់។

[11] សៀវភៅណែនាំស្តីពីការពិនិត្យដ៏ត្រឹមត្រូវរបស់ OECD ជាឯកសារយោងជាអន្តរជាតិដ៏សំខាន់ សម្រាប់ហានិភ័យប្រភេទទី១។ សៀវភៅណែនាំរបស់ ក៏ជាឯកសារយោង សម្រាប់បទដ្ឋាន និងបទបញ្ញត្តិអន្តរជាតិ ហើយមានលក្ខណៈសំខាន់ជាមួយនឹងការអនុលោមទៅតាមកាតព្វកិច្ចច្បាប់ពាណិជ្ជកម្ម និងទីផ្សារនានាដែលពួកគេត្រូវគោរពតាម ដែលរួមបញ្ចូលទាំង ឧទាហរណ៍ ក្រុមហ៊ុនចុះបញ្ជីទីផ្សារភាគហ៊ុននៅសហរដ្ឋអាមេរិក និងនៅតំបន់ Great Lakes អាហ្វ្រិក។

[12] គោលការណ៍ណែនាំរបស់ចិនស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ជាឯកសារយោងដ៏សំខាន់ សម្រាប់ហានិភ័យប្រភេទទី២។ គោលការណ៍ណែនាំស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ក្នុងប្រការទី ២.៣.១ ទាមទារពីក្រុមហ៊ុនរ៉ែរបស់ចិនឲ្យ "កំណត់នូវក្រមសីលធម៌

យុទ្ធសាស្ត្រនៃការកាត់បន្ថយហានិភ័យសម្រាប់ហានិភ័យប្រភេទនីមួយៗ ដែលមាននៅក្នុងប្រការពាក់ព័ន្ធ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ត្រូវបានបង្ហាញទៅតាមហានិភ័យនីមួយៗដូចខាងក្រោម។

## 5.1 ហានិភ័យប្រភេទទី១៖ ហានិភ័យទាំងឡាយណាដែលនាំឲ្យមានជម្លោះនិងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលអាចកើតចេញពីប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ និងការនាំចេញធនធានរ៉ែ នៅតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់

**5.1.1 ហានិភ័យក្នុងការប្រព្រឹត្ត ទទួលផលចំណេញពី ឬផ្តល់ជំនួយដល់ ឬសម្រុបសម្រប ឬទទួលប្រភពពី ឬមានទំនាក់ទំនងជាមួយភាគីណាមួយដែលប្រព្រឹត្ត ទទួលផលចំណេញពី ឬ ផ្តល់ជំនួយដល់ ឬសម្រុបសម្របនាំឲ្យមានការរំលោភបំពានធ្ងន់ធ្ងរណាមួយដូចខាងក្រោម៖**

5.1.1.1 ទម្រង់ណាមួយនៃការធ្វើទារុណកម្ម អមនុស្សធម៌ និងការបន្ទាបបន្ថោក

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.1.2 ទម្រង់ណាមួយនៃការប្រើកំលាំងពលកម្មដោយការបង្ខំ មានន័យថាការងារឬសេវាកម្មណាដែលបុគ្គលណាម្នាក់ធ្វើ ក្រោមការគំរាមកំហែងនៃការពិន័យ និងដែលបុគ្គលនោះធ្វើដោយមិនបានស្ម័គ្រចិត្ត។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.1.3 ទម្រង់ដែលធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៥.១ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.1.4 ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងទៀតដូចជា អំពើហិង្សាផ្លូវភេទ ឬបរាជ័យក្នុងការធានាមិនឲ្យមានការរំលោភសិទ្ធិមនុស្ស រួមនឹងការយកផលចំនេញ ឬ ទំនងជាបានទទួលផលប្រយោជន៍ ឬការបណ្តោយឲ្យ ឬទំនងជាបណ្តោយឲ្យមានការរំលោភសិទ្ធិមនុស្សដោយករណីផ្សេងទៀត។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.១ និង២.៤.២ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

---

មួយដែលតម្រូវឲ្យអ្នកផ្គត់ផ្គង់បំពេញនូវតម្រូវការ [ទាំងអស់] ដែលពាក់ព័ន្ធក្នុងគោលការណែនាំ [ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ] និងលើកទឹកចិត្តឲ្យអ្នកផ្គត់ផ្គង់ចុះហត្ថលេខាលើឯកសារនេះ។"

5.1.1.5 ឧក្រិដ្ឋកម្មសង្គ្រាមឬការរំលោភបំពានផ្សេងទៀតលើច្បាប់មនុស្សធម៌អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.១ និង២.៤.២ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

**5.1.2 ហានិភ័យក្នុងការផ្តល់ជំនួយដល់ ឬសម្របសម្រួល ឬទទួលប្រភពពី ឬមានទំនាក់ទំនងជាមួយភាគីណាមួយដែលផ្តល់ការគាំទ្រដោយផ្ទាល់ ឬដោយប្រយោល ដល់ក្រុមប្រដាប់អាវុធមិនមែនរដ្ឋ៖**

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.៦ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.2.1 ការជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោល ដល់ក្រុមប្រដាប់អាវុធខុសច្បាប់ទាំងឡាយតាមរយៈការប្រតិបត្តិ ដឹកជញ្ជូន ធ្វើពាណិជ្ជកម្ម ចម្រាញ់ ឬនាំចេញធនធានរ៉ែ។ នេះរួមបញ្ចូលទាំងការបញ្ជាទិញធនធាន ការចំណាយ ឬ ការផ្តល់ជំនួយភស្តុភារ ឬឧបករណ៍ផ្សេងៗទៅឲ្យក្រុមប្រដាប់អាវុធខុសច្បាប់ ឬ ដៃគូរបស់ពួកគេ ដែល៖

1. គ្រប់គ្រងតំបន់ប្រតិបត្តិការរ៉ែដោយខុសច្បាប់ ឬគ្រប់គ្រងផ្លូវដឹកជញ្ជូន ឬចំនុចដែលធនធានរ៉ែត្រូវធ្វើពាណិជ្ជកម្ម និងជាអ្នកដើរតួរចំបង នៅក្នុងខ្សែចង្វាក់ផលិតកម្មផ្នែកអាប់ស្ទ្រីម
2. យកពន្ធ ឬគំរាមយកប្រាក់ ឬធនធានរ៉ែដោយខុសច្បាប់ នៅកន្លែងប្រតិបត្តិការរ៉ែ នៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ
3. យកពន្ធ ឬគំរាមឈ្មួញកណ្តាល ក្រុមហ៊ុននាំចេញ ឬពាណិជ្ជករអន្តរជាតិដោយខុសច្បាប់

**5.1.3 ហានិភ័យដែលជាប់ទាក់ទងជាមួយនឹងកងកំលាំងសន្តិសុខឯកជន ឬសាធារណៈ**

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.២ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.3.1 ហានិភ័យក្នុងការផ្តល់ជំនួយដល់ ឬទទួលប្រភពពីឬមានទំនាក់ទំនងជាមួយភាគីណាមួយដែលផ្តល់ជំនួយដោយផ្ទាល់ ឬដោយប្រយោល ដល់កងកំលាំងសន្តិសុខសាធារណៈឬឯកជនដែលជាអ្នក៖

1. គ្រប់គ្រងតំបន់ប្រតិបត្តិការរ៉ែ ផ្លូវដឹកជញ្ជូន ដោយខុសច្បាប់ និង/ឬនិងជាអ្នកដើរតួរចំបងនៅក្នុងខ្សែចង្វាក់ផលិតកម្មផ្នែកអាប់ស្ទ្រីម
2. យកពន្ធ ឬគំរាមយកប្រាក់ ឬធនធានរ៉ែដោយខុសច្បាប់ នៅកន្លែងប្រតិបត្តិការរ៉ែ នៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ
3. យកពន្ធ ឬគំរាមឈ្មួញកណ្តាល ក្រុមហ៊ុននាំចេញ ឬពាណិជ្ជករអន្តរជាតិដោយខុសច្បាប់ ហើយមិនគោរពតាមនិតិរដ្ឋ និងសិទ្ធិមនុស្ស ឬព្រងើយកន្តើយបញ្ហាសុវត្ថិភាពរបស់បុគ្គលិក កម្មករ ឧបករណ៍ និងគ្រឿងបរិក្ខារផ្សេងៗ ព្រមទាំងការយកទីតាំងប្រតិបត្តិការរ៉ែ ឬផ្លូវដឹកជញ្ជូនពីប្រតិបត្តិការនិងការធ្វើពាណិជ្ជកម្មរ៉ែដែលស្របច្បាប់ ។

5.1.3.2 ការបរាជ័យក្នុងការធានាឲ្យបានថា កងកំលាំងទាំងនោះប្រតិបត្តិស្របទៅតាមបទដ្ឋាន ឬឯកសារណែនាំដែលទទួលស្គាល់ជាអន្តរជាតិ ស្តីអំពីកងកំលាំងសន្តិសុខឯកជន[13] ជាពិសេសការប្រើប្រាស់គោលនយោបាយផ្សេងៗ ក្នុងការត្រួតពិនិត្យ ដើម្បីធានាឲ្យប្រាកដថានឹងមិនមានការប្រើប្រាស់សេវាកម្មរបស់បុគ្គល ឬអង្គភាពនៃកងកំលាំងសន្តិសុខណា ដែលធ្លាប់មានប្រវត្តិរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនោះទេ ។

### 5.1.4 ហានិភ័យក្នុងការចូលរួមចំណែក ឬមានប្រភពពី ឬមានជាប់ទាក់ទងទៅនឹងភាគីណាមួយដែលចូលរួមពាក់ព័ន្ធនឹងការប្រព្រឹត្តខុសធ្ងន់ធ្ងរ៖

5.1.4.1 ធ្វើការស្នើ ផ្តល់ឲ្យ សន្យា ឬ ទាមទារសំណូកណាមួយ ឬ ផលប្រយោជន៍ផ្សេងទៀតដែលមិនត្រឹមត្រូវ និង/ឬសុំឲ្យគេសូកប៉ាន់ ដើម្បីបិទបាំង ឬក្លែងបន្លំនូវប្រភពដើមរបស់ធនធានរ៉ែ បន្លំការបង់ពន្ធ ថ្លៃឈ្នួលនិងកម្រៃសួយសារដែលត្រូវបង់ជូនរដ្ឋាភិបាល សម្រាប់ប្រតិបត្តិការ ពាណិជ្ជកម្ម ការដឹកជញ្ជូន និងការនាំចេញធនធានរ៉ែ ឬមិនបានគោរពតាមបទដ្ឋានអន្តរជាតិ និងអនុសញ្ញាស្តីអំពីការប្រឆាំងអំពើពុករលួយ។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.២.២ និង២.២.៣ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

---

[13] បទដ្ឋាន ឬឯកសារណែនាំដែលទទួលស្គាល់ជាអន្តរជាតិ ស្តីអំពី កងកំលាំងសន្តិសុខឯកជន មានដូចជាគោលការណ៍គ្រឹះស្ម័គ្រចិត្តស្តីអំពីសន្តិសុខនិងសិទ្ធិមនុស្ស "ឯកសារ Montreux ពាក់ព័ន្ធនឹងកាតព្វកិច្ចផ្លូវច្បាប់អន្តរជាតិ និងការអនុវត្តល្អសម្រាប់រដ្ឋ ទាក់ទងទៅនឹងប្រតិបត្តិការរបស់យោធាឯកជន និងក្រុមហ៊ុនសន្តិសុខ កំឡុងពេលមានជម្លោះប្រដាប់អាវុធ" "ក្រមអនុវត្តអន្តរជាតិ សម្រាប់អ្នកផ្តល់សេវាកម្មសន្តិសុខអន្តរជាតិ (ICoC)" "ឯកសារ ANSI/ASIS PSC.1 ប្រព័ន្ធគ្រប់គ្រងគុណភាពនៃប្រតិបត្តិការក្រុមហ៊ុនសន្តិសុខឯកជន (PSC.1) ក៏ដូចជាបទដ្ឋាន ISO 18788 ប្រព័ន្ធគ្រប់គ្រងប្រតិបត្តិការសន្តិសុខឯកជន"

5.1.4.2 ជាប់ទាក់ទងនឹងការលាងលុយដែលបានមកពី ឬមានការពាក់ព័ន្ធនឹងប្រតិបត្តិការពាណិជ្ជកម្ម ការចម្រាញ់ ការដឹកជញ្ជូន ឬការនាំចេញធនធានរ៉ែ ដែលមានប្រភពពីការបង់ពន្ធខុសច្បាប់ ឬការប្លន់យកធនធានរ៉ែ ក្នុងគ្រប់ចំនុចឆ្លងកាត់តំបន់ប្រតិបត្តិការធនធានរ៉ែ និងនៅតាមផ្លូវដឹកជញ្ជូន ឬនៅគ្រប់ចំណុចដែលធនធានរ៉ែត្រូវបានធ្វើពាណិជ្ជកម្មដោយអ្នកផ្គត់ផ្គង់ផ្នែកអាប់ស្ទ្រីម

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.២.៥ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.1.4.3 គេចវេស ឬក្លែងបន្លំពន្ធ ថ្លៃឈ្នួលនិងកម្រៃសួយសារ ឬការចំណាយផ្សេងៗទៀត ជាមួយរដ្ឋាភិបាល ទាក់ទងទៅនឹងប្រតិបត្តិការ ពាណិជ្ជកម្ម និងការនាំចេញធនធានរ៉ែ ពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះនិងមានហានិភ័យខ្ពស់ និងមិនបានបើកចំហនូវរាល់ការចំណាយទាំងនោះដោយអនុលោមទៅតាម គោលការណ៍ដែលបានកំណត់ ក្រោមគំនិតផ្តួចផ្តើមដើម្បីតម្លាភាពក្នុងវិស័យឧស្សាហកម្មនិស្សារណកម្ម ឬគំនិតផ្តួចផ្តើមតម្លាភាពដែលពាក់ព័ន្ធផ្សេងៗទៀត។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.២.៥ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

## 5.2 ហានិភ័យប្រភេទទី២៖ ហានិភ័យទាំងឡាយណាដែលទាក់ទងទៅនឹងការប្រព្រឹត្តខុសធ្ងន់ធ្ងរទៅលើបញ្ហាបរិស្ថាន សង្គម និងក្រមសីលធម៌

### 5.2.1 ហានិភ័យក្នុងការចូលរួមចំណែក ឬមានប្រភពពី ឬមានជាប់ទាក់ទងទៅនឹងភាគីណាមួយដែលចូលរួមពាក់ព័ន្ធនឹងការប្រព្រឹត្តខុសធ្ងន់ធ្ងរ៖

5.2.1.1 ល្មើសច្បាប់ និងបទប្បញ្ញត្តិរបស់ប្រទេសចិន ឬរបស់ប្រទេសសាមី ឬបទដ្ឋានឧស្សាហកម្មអប្បបរមា

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ១.១ និង១.៣ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.2 ផ្តល់ការងារឲ្យកុមារក្រោមអាយុការងារស្របច្បាប់អប្បបរមា ដូចដែលបានចែងដោយច្បាប់និងបទប្បញ្ញត្តិរបស់ប្រទេសសាមី ឬក្នុងករណីមិនមានច្បាប់និងបទបញ្ញត្តិពាក់ព័ន្ធរបស់ប្រទេសសាមីនោះទេ ការផ្តល់ការងារឲ្យកុមារដែលមានអាយុក្រោម១៦ឆ្នាំ[14] ។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៥.១ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

[14] គួរកត់សម្គាល់ផងដែរថា អាយុអប្បបរមាដែលអនុញ្ញាតឲ្យចូលបម្រើ ឬធ្វើការងារ ដែលលក្ខណៈ ឬលក្ខខណ្ឌនៃការងារនោះ អាចនឹងបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព ឬសីលធម៌របស់កុមារ គឺមិនត្រូវតិចជាងអាយុ១៨ឆ្នាំនោះឡើយ។

5.2.1.3 រំលោភបំពានសិទ្ធិ និងផលប្រយោជន៍របស់កម្មកររយៈក្មេង (កម្មករណាដែលមានអាយុលើសពីអាយុការងារស្របច្បាប់អប្បបរមា និងដែលមានអាយុក្រោម១៨ឆ្នាំ)

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៥.១ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.4 ប្រតិបត្តិការ ឬយកប្រភពធនធានរ៉ែពី ដីតំបន់ដែលមិនទទួលបានការព្រមព្រៀងជាមុនដោយសេរី និងមានការផ្តល់ព័ត៌មានគ្រប់គ្រាន់ ពីសហគមន៍មូលដ្ឋាន និងជនជាតិភាគតិច រួមមានទាំងអ្នកដែលកាន់កាប់កម្មសិទ្ធ ការជួល សម្បទាន ឬអាជ្ញាប័ណ្ណស្របច្បាប់[15] ។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.៥ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.5 កាប្រតិបត្តិការ ឬយកប្រភពធនធានរ៉ែពីតំបន់ប្រតិបត្តិការធនធានរ៉ែ ដែលនៅតំបន់នោះវប្បធម៌និងបេតិកភ័ណ្ឌរបស់សហគមន៍មូលដ្ឋាននិងជនជាតិដើមភាគតិច មិនទទួលបានការគោរពនិងការការពារ ឬកន្លែងដែលប្រពៃណីវប្បធម៌របស់សហគមន៍មូលដ្ឋាន មានការរងប៉ះទង្គិច។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.៤ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.6 ប្រតិបត្តិការ ឬយកប្រភពធនធានរ៉ែពីដីតំបន់ដែលកម្មសិទ្ធស្របច្បាប់ ការជួល សម្បទាន ឬអាជ្ញាប័ណ្ណ ទទួលបានដោយខុសច្បាប់ ឬរំលោភច្បាប់ជាតិ ឬតំបន់ដែលមានអំណះអំណាងស្របច្បាប់ពីមុនលើកម្មសិទ្ធិដីដោយប្រជាជនមូលដ្ឋាន រាប់បញ្ចូលទាំងតំបន់ណាដែលមានទំនៀមទម្លាប់ប្រពៃណី ឬប្រព័ន្ធកម្មសិទ្ធិកាន់កាប់ដីរួមគ្នា ឬតំបន់ណាដែលប្រជាជនតាំងទីលំនៅនៅក្នុងតំបន់ប្រតិបត្តិការរ៉ែ ត្រូវបានផ្លាស់ប្តូរទីលំនៅដោយមិនមានការស្ម័គ្រចិត្ត។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៤.៣ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

[15] ទស្សនទាននៃការព្រមព្រៀងដោយសេរី ជាមុន ដែលមានការផ្តល់ព័ត៌មានគ្រប់គ្រាន់ មានរៀបរាប់ និងពន្យល់បន្ថែមនៅក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិរបស់ជនជាតិដើមភាគតិច (UNDRIP)។ មាត្រាទី១០ នៃ UNDRIP ចែងថា៖ "ជនជាតិដើមភាគតិចមិនត្រូវបានគេបណ្តេញដោយបង្ខំចេញពីដីធ្លី ឬដែនដីរបស់ខ្លួនឡើយ។ ការតាំងលំនៅថ្មី មិនត្រូវធ្វើដោយគ្មានការយល់ព្រមដោយសេរី និងដោយមិនបានប្រាប់ឲ្យដឹងជាមុនដល់ជនជាតិដើមភាគតិចពាក់ព័ន្ធ និងបន្ទាប់ពីមានការព្រមព្រៀងលើសំណងដែលត្រឹមត្រូវ និងយុត្តិធម៌នោះឡើយ ហើយបើសិនជាធ្វើទៅបាន ត្រូវដាក់ឲ្យមានជម្រើសនៃការវិលត្រលប់មកកាន់ដីធ្លី ឬដែនដីរបស់ខ្លួនវិញ។" មាត្រាទី ១១.២ បានចែងបន្ថែមទៀតថា "រដ្ឋទាំងឡាយ ត្រូវផ្តល់ឲ្យមានដំណោះស្រាយតាមរយៈយន្តការមានប្រសិទ្ធភាព ដែលរួមមានទាំងបដិទាន ដោយបានរៀបចំបង្កើតឡើងជាមួយជនជាតិដើមភាគតិច ចំពោះកម្មសិទ្ធិវប្បធម៌ បញ្ញា សាសនា និង ជំនឿរបស់ពួកគេដែលត្រូវបានដកហូតដោយគ្មានការយល់ព្រមព្រៀងដោយសេរី និងដោយមិនបានប្រាប់ឲ្យដឹងជាមុន ឬដែលរំលោភលើច្បាប់ ប្រពៃណីនិងទំនៀមទម្លាប់របស់ពួកគេ។ គោលការណ៍បន្ថែមទៀត គឺបានផ្តល់ដោយ FAO និងក្នុងសេចក្តីថ្លែងការណ៍របស់ ICMM ស្តីអំពីជនជាតិដើមភាគតិច និងប្រតិបត្តិការរ៉ែ ។

5.2.1.7 ផលប៉ះពាល់អវិជ្ជមាន និងការរំលោភច្បាប់អន្តរជាតិ និងច្បាប់បទប្បញ្ញត្តិជាតិធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងលក្ខខណ្ឌសមស្របនៃបរិយាកាសដី ខ្យល់ និងទឹក រួមទាំងការផលិត ពាណិជ្ជកម្ម និងការប្រើប្រាស់សារធាតុគីមីពុល និងសារធាតុគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់ជាអន្តរជាតិ ដោយសារតែកម្រិតជាតិពុលខ្ពស់របស់សារធាតុទាំងនោះ មកលើសារពាង្គកាយមានជីវិត បរិស្ថាន ឬផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានឡើងលើប្រព័ន្ធអេកូឡូស៊ី និង/ឬការបញ្ចេញសារធាតុអាសេនិច និងការបំភាយសារធាតុបារត។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៧.៥ និង២.៧.៩ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.8 ការបរាជ័យក្នុងការបញ្ចៀស កាត់បន្ថយ ឬប្រសិនបើផលប៉ះពាល់ដែលសេសសល់នៅតែមាន ត្រូវធ្វើការទូទាត់សងលើផលប៉ះពាល់ចំពោះបរិស្ថាន និងប្រព័ន្ធអេកូឡូស៊ី ក្នុងរយៈពេលវដ្តជីវិតនៃប្រតិបត្តិការរ៉ែ ដោយធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញជាក់លាក់ កាត់បន្ថយកាកសំណល់និងការបំភាយ ធានាឲ្យមានការបិទអណ្តូងរ៉ែ និងការស្តារឡើងវិញតំបន់រ៉ែ អភិរក្សធនធាននិងការកែឆ្នៃឡើងវិញ អនុវត្តផែនការគ្រប់គ្រងហានិភ័យបរិស្ថាន ចូលរួមចំណែកដល់ការអភិរក្សជីវចម្រុះ និងស្វែងរកវិធីធ្វើឲ្យប្រសើរឡើងជាបន្តបន្ទាប់នៃការអនុវត្តកម្មវិធីបរិស្ថានរបស់ពួកគេ។ ការទូទាត់សង គួរជាជំរើសចុងក្រោយ និងត្រូវបានអនុវត្តតែក្នុងករណីដែលកិច្ចខំប្រឹងប្រែងទាំងអស់ក្នុងការបញ្ចៀស ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ត្រូវបានប្រើប្រាស់អស់លទ្ធភាព[16] ។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៧ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.9 ប្រតិបត្តិការ ឬ ទទួលយកប្រភពធនធានរ៉ែពីពីតំបន់បេតិកភណ្ឌពិភពលោក (WHS) ឬតំបន់ការពារស្របច្បាប់ ឬប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ទ្រនាប់នៃ WHS ឬនៃតំបន់ការពារ ឬធ្វើការដឹកជញ្ជូនធនធានរ៉ែ នៅក្នុងតំបន់ WHS ឬតំបន់ការពារ ដែលបណ្តាលឲ្យមានការគំរាមកំហែងដល់គុណតម្លៃសំខាន់ជាសកល ដែលត្រូវបានការពារនៅក្នុងតំបន់ទាំងនោះ[17] ។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.៧.១៣ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

---

[16] ក្រុមហ៊ុន អាចប្រើប្រាស់នីតិវិធី (PS6) សម្រាប់ការណែនាំបន្ថែម លើការអនុវត្តដ៏ប្រសើរបំផុត សម្រាប់ការអភិរក្សជីវៈចម្រុះនិងការគ្រប់គ្រងធនធានធម្មជាតិដែលមានជីវិតប្រកបដោយនិរន្តរភាព។ យ៉ាងហោចណាស់ ប្រទេសដែលសម្បូរធនធានមួយក្នុងទ្វីបអាហ្វ្រិក (ប្រទេសលីបេរីយ៉ា) ថ្មីៗនេះបានតម្រូវឲ្យក្រុមហ៊ុនទាំងអស់ដែលប្រតិបត្តិការក្នុងប្រទេសរបស់ខ្លួន រាប់បញ្ចូលទាំងក្រុមហ៊ុនឧស្សាហកម្មរ៉ែ អនុម័តនិងអនុវត្ត PS6 ។ ប្រទេសផ្សេងៗទៀតអាចនឹងយកគំរូតាមប្រទេសលីបេរីយ៉ា ។

[17] មហាសន្និបាតអង្គការ UNESCO នៅថ្ងៃទី ១៦ វិច្ឆិកា ១៩៧២ បានអនុម័តអនុសញ្ញាទាក់ទងនឹងការការពារបេតិកភ័ណ្ឌធម្មជាតិ និងវប្បធម៌ពិភពលោក ដែលជាសេចក្តីយោងជាសកលសម្រាប់ការការពារបេតិកភណ្ឌពិភពលោក ។

5.2.1.10 បរាជ័យក្នុងការរៀបចំរបាយការណ៍ឲ្យបានទៀងទាត់ និងទាន់ពេលវេលាទៅឲ្យអ្នកពាក់ព័ន្ធ ពីបញ្ហាផលប៉ះពាល់របស់ពួកគេ និងការបើកចំហពីប្រតិបត្តិលើសីលធម៌ សង្គមនិងបរិស្ថានរបស់ខ្លួនទៅដល់អ្នកពាក់ព័ន្ធរបស់ពួកគេ ទៅតាមភាពសមស្រប និងមានអត្ថន័យជាមួយនឹងតម្រូវការរបស់ពួកគេ។ នេះរួមបញ្ចូលទាំងទិដ្ឋភាពជាក់លាក់លើគោលនយោបាយ ហានិភ័យ និងលទ្ធផលសម្រេចបានរបស់ពួកគេ ទាក់ទងទៅនឹងបញ្ហានៃឥរិយាបថ បរិស្ថាន និងសង្គម។ វារួមបញ្ចូលផងដែរ នូវការសំណូមពរ ការគោរព និងការឆ្លើយតបដោយសកម្មទៅនឹងការផ្តល់យោបល់ និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធ ក្នុងនោះមានអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន។

(ចំណុចនេះពាក់ព័ន្ធនឹងប្រការ ២.១.៥ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ)

5.2.1.11 បរាជ័យក្នុងការអនុវត្តជំហានដោយសកម្ម ដើម្បីគោរពតាមគោលការណ៍គ្រឹះទាំងអស់ផ្សេងទៀតដែលមានចែង ក្នុងគោលការណ៍ណែនាំរបស់ចិនស្តីពីទំនួលខុសត្រូវ ក្នុងការវិនិយោគរ៉ែដែលមិនស្ថិតនៅក្នុងហានិភ័យប្រភេទទី១ ឬហានិភ័យដទៃទៀតដែលមិនបានរៀបរាប់ខាងលើ។

# ៦. សញ្ញាព្រមាន

ដូចដែលបានរៀបរាប់នៅក្នុងមាតិកាចំណុចទី៥ កត្តាជម្រុញឲ្យមានការពិនិត្យដ៏ត្រឹមត្រូវដែលប្រសើរគឺអាស្រ័យទៅលើវត្តមាននៃហានិភ័យនៅក្នុងខ្សែចង្វាក់ផលិតកម្ម។ យ៉ាងណាក៏ដោយ ទីតាំងនៃប្រភពដើមធនធានរ៉ែ អាចផ្ដល់ការចង្អុលបង្ហាញយ៉ាងសំខាន់ដែលជួយដល់ក្រុមហ៊ុន តាមរយៈកិច្ចប្រឹងប្រែងដោយសកម្មរបស់ពួកគេ ក្នុងការកំណត់ថាតើហានិភ័យទាំងនោះ ទំនងជាកើតឡើងក្នុងពេលប្រតិបត្តិការ ពាណិជ្ជកម្ម ឬតាមរយៈការប្រើប្រាស់ធនធានរ៉ែ បង្កឲ្យមានជម្លោះ ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ និង/ឬ ការប្រព្រឹត្តខុសដោយធ្ងន់ធ្ងរ។

ដូចនេះហើយ ជាផ្នែកមួយនៃការពិនិត្យដ៏ត្រឹមត្រូវរបស់ពួកគេ វាជាការចាំបាច់សម្រាប់រាល់ក្រុមហ៊ុនចិនទាំងអស់ដែលប្រតិបត្តិការផ្នែកអាប់ស្ទ្រីម ត្រូវរៀបចំប្រព័ន្ធនានាជាស្រេច ដែលអាចឲ្យពួកគេប្រមូលយកពត៌មានគ្រប់គ្រាន់ជាប្រចាំ ដើម្បីដឹងពីប្រភពផ្គត់ផ្គង់នៃធនធានរ៉ែ ពីទីតាំងជាក់លាក់ដែលរាប់បញ្ចូលទាំងតំបន់ប្រតិបត្តិការរ៉ែ តំបន់ធ្វើពាណិជ្ជកម្មរ៉ែ និងផ្លូវដឹកជញ្ជូន[18] ។

ក្រុមហ៊ុនចិនទាំងអស់ដែលប្រតិបត្តិការផ្នែកដោនស្ទ្រីម ចាំបាច់ត្រូវរៀបចំជាប្រចាំនិង ប្រកបដោយកិច្ចប្រឹងប្រែងសុចន្ទៈនិងសមស្រប នូវប្រព័ន្ធដែលមានតម្លាភាព ក្នុងការកំណត់ និងមានទំនាក់ទំនងជាមួយក្រុមហ៊ុនទាំងឡាយណាដែលនៅក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ ដើម្បីអាចឲ្យពួកគេកំណត់ឲ្យបាននូវសញ្ញាព្រមាននៅក្នុងខ្សែចង្វាក់ផលិតកម្ម និងដើម្បីពង្រីកអានុភាពជាមួយតួអង្គនៅផ្នែកអាប់ស្ទ្រីមក្នុងការកាត់បន្ថយហានិភ័យ។

[18]បុគ្គលិកក្រុមហ៊ុនគួរតែពឹងផ្អែកលើប្រភពពត៌មានរបស់ពួកគេផ្ទាល់ ក្នុងការកំណត់ហានិភ័យនៃខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ។ ទោះបីជាយ៉ាងណា មានប្រភពផ្សេងៗ ដែលអាចជួយបុគ្គលិកក្រុមហ៊ុនក្នុងការកំណត់ហានិភ័យទាំងនោះ។ អង្គការ OECD ផ្ដល់យោបល់ឲ្យក្រុមហ៊ុនទាំងនោះឲ្យ "ពិនិត្យមើលនូវរបាយការណ៍សិក្សាស្រាវជ្រាវពីរដ្ឋាភិបាល អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងសារពត៌មាន ផែនទី សេចក្ដីរាយការណ៍របស់ UN និង ការដាក់ទណ្ឌកម្មរបស់ក្រុមប្រឹក្សាសន្តិសុខរបស់ UN ឯកសារតោមវិស័យដែលទាក់ទងទៅនឹង ប្រតិបត្តិការរ៉ែ និងផលប៉ះពាល់របស់វាលើជម្លោះ សិទ្ធិមនុស្ស ឬការគំរាមកំហែងលើបរិស្ថានក្នុងប្រទេសដែលអាចជាប្រភពធនធានរ៉ែ ឬសេចក្ដីថ្លែងការណ៍ជាសាធារណៈផ្សេងទៀត។" ក្រុមហ៊ុនគួរតែមើលពីលក្ខណៈវិនិច្ឆ័យ និងសូចនាករណានៃតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ ដែលបង្កើតឡើងដោយគំនិតផ្ដួចផ្ដើមពហុភាគី រួមទាំងការសិក្សាដែលកំពុងធ្វើ ពាក់ព័ន្ធទៅនឹងការអនុវត្តគោលការណែនាំនេះ ដែលត្រូវបានសម្របសម្រួលដោយ OECD ។

មិនមានការកំណត់ជាក់លាក់ណាមួយដែលត្រូវបានព្រមព្រៀងសកលថា តើតំបន់ណាដែលចាត់ចូលជាតំបន់ដែលរងប៉ះពាល់ដោយជម្លោះ ឬតំបន់មានហានិភ័យខ្ពស់នោះទេ។ ភាគច្រើនតំបន់ដែលរងប៉ះពាល់ដោយជម្លោះនិងតំបន់មានហានិភ័យខ្ពស់ មានលក្ខណៈពិសេសរួមមួយ ឬច្រើនដូចខាងក្រោម៖

1. វត្តមាននៃជម្លោះប្រដាប់អាវុធ (ជម្លោះប្រដាប់អាវុធអាចនឹងកើតឡើងដោយទម្រង់ខុសគ្នា ដូចជាជម្លោះអន្តរជាតិ ឬមិនមែនជាអន្តរជាតិ ដែលជាប់ពាក់ព័ន្ធរវាងប្រទេសពីរ ឬច្រើន ឬអាចឲ្យមានសង្គ្រាមរំដោះខ្លួន ឬកុដកម្មសង្គ្រាម ឬសង្គ្រាមស៊ីវិល)
2. វត្តមាននៃការផ្ទុះអំពើហិង្សា រួមទាំងអំពើហិង្សាដែលបង្កដោយបណ្តាញឧក្រិដ្ឋជន
3. តំបន់ដែលងាយរងគ្រោះក្រោយជម្លោះ
4. តំបន់ដែលមានអភិបាលកិច្ចទន់ខ្សោយ ឬមិនមានអភិបាលកិច្ច និងសន្តិសុខ
5. តំបន់ដែលមានការរំលោភច្បាប់អន្តរជាតិខ្លាំងក្លា និងមានលក្ខណៈជាប្រព័ន្ធរួមទាំងការរំលោភសិទ្ធិមនុស្ស
6. តំបន់ដែលមានការរើសអើងជាប្រព័ន្ធ លើក្រុមមនុស្សណាមួយ
7. តំបន់ដែលមានជំងឺពុករលួយ
8. តំបន់ដែលមានការរំលោភបំពានលើផ្លូវភេទនិងហិង្សាយែនឌ័រ

ចំពោះគោលការណ៍ណែនាំនេះ តំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងតំបន់ដែលមានហានិភ័យខ្ពស់ អាចត្រូវបានពន្យល់ថា ជាតំបន់ណាមួយដែលកំណត់ដោយ ការកើតមានឡើងនូវជម្លោះប្រដាប់អាវុធ ការផ្ទុះអំពើហិង្សា រាប់បញ្ចូលទាំងហិង្សាដែលបង្កដោយបណ្តាញឧក្រិដ្ឋជន ឬហានិភ័យផ្សេងទៀត ដែលបង្កឲ្យមានគ្រោះថ្នាក់រីករាលដាល និងធ្ងន់ធ្ងរដល់មនុស្ស។ តំបន់ទាំងនោះ ជាញឹកញាប់ត្រូវបានកំណត់លក្ខណៈ ដោយអស្ថេរភាពនយោបាយឬការបង្ក្រាប ភាពទន់ខ្សោយនៃស្ថាប័ន អសន្តិសុខ ការដួលរលំនៃហេដ្ឋារចនាសម្ព័ន្ធស៊ីវិល ការផ្ទុះអំពើហិង្សា និង ការរំលោភច្បាប់ជាតិនិងអន្តរជាតិ ក៏ដូចជាការរាតត្បាតនៃអំពើពុករលួយ ផលប៉ះពាល់ធ្ងន់ធ្ងរលើបរិស្ថាន ព្រមទាំងការរំលោភសិទ្ធិដីធ្លី។

នៅពេលដែលធ្វើការពិនិត្យដ៏ត្រឹមត្រូវដែលប្រសើរ ក្នុងជំហានទី២ និងទី៣ ក្រុមហ៊ុនចិនទាំងអស់ដែលកំពុងប្រតិបត្តិការរ៉ែ ធ្វើពាណិជ្ជកម្ម ចម្រាញ់ ដឹកជញ្ជូន និង/ឬកំពុងប្រើប្រាស់ធនធានរ៉ែ និងផលិតផលផ្សេងៗនៃធនធានរ៉ែនោះ និងមានពាក់ព័ន្ធនៅក្នុងដំណាក់កាលណាមួយ នៅក្នុងខ្សែចង្វាក់

ផលិតកម្មធនធានរ៉ែ ត្រូវព្យាយាមដោយសុចន្ទៈ ដើម្បីកំណត់នូវវត្តមាននៃ "សញ្ញាព្រមាន" ណាមួយ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ ដូចខាងក្រោម ៖

| | |
|---|---|
| សញ្ញាព្រមាន នៃទីតាំងនៃប្រភពដើមនិងទីតាំងឆ្លងកាត់របស់ធនធាន | 1. ធនធានរ៉ែដែលមានប្រភពដើមពី ឬបានដឹកជញ្ជូនតាមតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងតំបន់ដែលមានហានិភ័យខ្ពស់។<br>2. ធនធានដែលបានអះអាងមាន ប្រភពពីប្រទេសមួយដែលធនធានបម្រុង ឬស្តុកទុកមានកំរិត ឬលទ្ធភាពផលិតកម្មនៃធនធានរ៉ែ ស្ថិតនៅក្នុងការសង្ស័យ ។<br>3. ធនធានដែលបានអះអាងមាន ប្រភពពីប្រទេសណាមួយដែលត្រូវបានដឹងថា ឬសង្ស័យថាអនុញ្ញាតឲ្យមានការឆ្លងកាត់ធនធានមកពីតំបន់ដែលរងផលប៉ះពាល់ដោយជម្លោះ និងតំបន់ដែលមានហានិ-ភ័យខ្ពស់ ។<br>4. ធនធានដែលបានអះអាងមានប្រភពសេសសល់/ការកែច្នៃ ឬប្រភពចំរុះ ហើយត្រូវបានធ្វើការចម្រាញ់នៅក្នុងប្រទេសណាមួយ ដែលត្រូវបានសង្ស័យថាជាកន្លែងដែលធនធានពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងដែលមានហានិភ័យខ្ពស់ ត្រូវបានឆ្លងកាត់ ។<br>5. ធនធានរ៉ែ ដែលមានប្រភពដើមពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងដែលមានហានិភ័យខ្ពស់ ដែលជាតំបន់ដែលទទួលរងការបំផ្លិចបំផ្លាញបរិស្ថាន ទ្រង់ទ្រាយធំ ជាទីតាំងតំបន់បេតិកភ័ណ្ឌពិភពលោក ជាតំបន់មានការរំលោភសិទ្ធិដីធ្លី ឬជាតំបន់ដែលមានទម្រង់រំលោភពលកម្មកុមារអាក្រក់បំផុត។ |
| សញ្ញាព្រមានក្រុមហ៊ុនផ្គត់ផ្គង់ | 1. ក្រុមហ៊ុនផ្គត់ផ្គង់ ឬក្រុមហ៊ុនផ្នែកអាប់ស្ទ្រីម ដទៃទៀតដែលមានប្រតិបត្តិការ ក្នុងតំបន់ដែលមានសញ្ញាព្រមានដូចបានរៀបរាប់ខាងលើ ឬមានភាគហ៊ុន ឬផលប្រយោជន៍ផ្សេងៗជាមួយក្រុមហ៊ុនផ្គត់ផ្គង់ ដែលមានសញ្ញាព្រមានណាមួយ ដូចបានរៀបរាប់ខាងលើ។<br>2. ក្រុមហ៊ុនផ្គត់ផ្គង់ ឬក្រុមហ៊ុនផ្នែកអាប់ស្ទ្រីមដទៃទៀតដែលធ្លាប់ទិញពីទីតាំងដែលមានសញ្ញាព្រមានណាមួយដូចបានរៀបរាប់ខាងលើ។ |
| សញ្ញាព្រមានទៅតាមហេតុការណ៍ | ភាពមិនប្រក្រតី ឬកាលៈទេសៈមិនប្រក្រតីដែលត្រូវបានរកឃើញ តាមរយៈពត៌មានដែលប្រមូលបាននៅក្នុង ជំហានទី១ បង្កើនភាពសង្ស័យសមស្របណាមួយ ថាធនធានរ៉ែអាចនឹងជាប់ទាក់ទងទៅនឹងការបង្កជម្លោះ ឬការរំលោភបំពាន់ធ្ងន់ធ្ងរ ពីការប្រតិបត្តិការ ការដឹកជញ្ជូន ឬពាណិជ្ជកម្មនៃធនធាននោះ ។ |

ការទទួលទិញ ឬប្រតិបត្តិការធនធានរ៉ែនៅក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ ឬដែលមានហានិ-ភ័យខ្ពស់ មិនគួរនាំឲ្យមានភាពសង្ស័យ ឬការបញ្ឈប់ការទទួលទិញពីតំបន់នោះទេ។ ព័តមានពីទីតាំងដែលធនធានមានប្រភពចេញពី ជាកត្តាមួយ ដើម្បីជួយដល់ក្រុមហ៊ុនកំណត់និងគ្រប់គ្រងហានិភ័យនៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ។ ក្រុមហ៊ុនទាំងឡាយត្រូវបានលើកទឹកចិត្ត ឲ្យរក្សាប្រតិបត្តិការរបស់ខ្លួននៅក្នុងតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងដែលមានហានិភ័យខ្ពស់ ព្រមទាំងរក្សាទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ ដើម្បីគ្រប់គ្រង ឬកាត់បន្ថយហានិភ័យ។

ប្រសិនបើដំណើរការនៃការពិនិត្យដ៏ត្រឹមត្រូវ នៅក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ មានលេចឡើងនូវ "សញ្ញាព្រមាន" និង/ឬ ហានិភ័យត្រូវបានកំណត់នៅក្នុងដំណាក់កាលណាមួយនៃខ្សែចង្វាក់ផលិតកម្មនោះ មានជម្រើសមួយចំនួន ដែលក្រុមហ៊ុនអាចប្រើប្រាស់ ដើម្បីគ្រប់គ្រង ឬកាត់បន្ថយហានិភ័យទាំងនេះ ជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់។ ជម្រើសទាំងនេះរួមមានៈ

1. បន្តការធ្វើពាណិជ្ជកម្ម តាមរយៈកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យ
2. ផ្អាកការធ្វើពាណិជ្ជកម្មជាបណ្តោះអាសន្ន ដោយបន្តកាត់បន្ថយហានិភ័យ។
3. បញ្ឈប់ការធ្វើពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់ បន្ទាប់ពីពួកគេបរាជ័យក្នុងការកាត់បន្ថយហានិភ័យ ឬនៅពេលដែលវិធីកាត់បន្ថយហានិភ័យរបស់ក្រុមហ៊ុនទាំងនោះ មិនអាចធ្វើទៅបាន ឬហានិភ័យមិនអាចទទួលយកបាន។

# ៧. ក្របខ័ណ្ឌ និងដំណើរការនៃការពិនិត្យដ៏ត្រឹមត្រូវ

ខណៈពេលដែលដំណើរការ និងតម្រូវការនៃការពិនិត្យដ៏ត្រឹមត្រូវ មានលក្ខណៈខុសគ្នាអាស្រ័យលើធនធានរ៉ែនិងតួនាទីរបស់ក្រុមហ៊ុននៅក្នុងខ្សែចង្វាក់ផលិតកម្ម ក្រុមហ៊ុនត្រូវពិនិត្យឡើងវិញនូវជម្រើសនៃអ្នកផ្គត់ផ្គង់ និងការសម្រេចចិត្តក្នុងការទទួលទិញរ៉ែ ហើយត្រូវដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងរបស់ពួកគេ នូវក្របខ័ណ្ឌជំហានទាំង៥ ចំពោះការពិនិត្យដ៏ត្រឹមត្រូវដែលផ្អែកលើហានិភ័យ នៅក្នុងខ្សែចង្វាក់ផលិតកម្មធនធានធម្មជាតិប្រកបដោយទំនួលខុសត្រូវ។ ជំហានទាំង៥នេះនឹងត្រូវពន្យល់ដោយលម្អិតថែមទៀត នៅក្នុងនិតិវិធីសវនកម្មសម្រាប់ធនធានជាក់លាក់ និងឯកសារបន្ថែមដែលជាឧបសម្ព័ន្ធនៃគោលការណ៍ណែនាំនេះ ឬនឹងត្រូវភ្ជាប់នៅក្នុងឧបសម្ព័ន្ធនាពេលក្រោយ។

## ៧.១ .បង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យដ៏ត្រឹមត្រូវ។ ក្រុមហ៊ុនត្រូវ៖

៧.១.១ អនុម័ត និងទំនាក់ទំនងជាមួយក្រុមហ៊ុនផ្គត់ផ្គង់ និងសាធារណៈ នូវគោលនយោបាយរបស់ក្រុមហ៊ុន ទៅលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែដែលមានប្រភពមកពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់។ គោលនយោបាយនេះ ត្រូវដាក់បញ្ចូលនូវបទដ្ឋានដែលត្រូវផ្ទៀងផ្ទាត់ ក្នុងការធ្វើការពិនិត្យដ៏ត្រឹមត្រូវ ហើយដែលត្រូវស្របទៅតាមបទដ្ឋានផ្សេងទៀតដែល បានកំណត់នៅក្នុងគោលនយោបាយខ្សែចង្វាក់ផលិតកម្មគំរូ ក្នុងឧបសម្ព័ន្ធ។

៧.១.២ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងផ្ទៃក្នុង ដើម្បីធ្វើការពិនិត្យដ៏ត្រឹមត្រូវនៃខ្សែចង្វាក់ផលិតកម្ម

៧.១.៣ បង្កើតនូវ ប្រព័ន្ធត្រួតពិនិត្យ និងតម្លាភាពលើខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ។

**ក្រុមហ៊ុនប្រតិបត្តិការផ្នែកអាប់ស្ទ្រីម** ត្រូវបង្កើតប្រព័ន្ធខ្សែសង្វាក់នៃការគ្រប់គ្រង ឬប្រព័ន្ធតាមដានសមស្រប សម្រាប់ផលិតកម្មនិងពាណិជ្ជកម្មធនធានរ៉ែ និងផ្តល់ព័ត៌មាននៃការពិនិត្យដ៏ត្រឹមត្រូវ ទៅក្រុមហ៊ុនផ្នែកដោនស្ទ្រីម។ លើសពីនេះទៀត ក្រុមហ៊ុនផ្នែកអាប់ស្ទ្រីម ត្រូវបានលើកទឹកចិត្តឲ្យទំនាក់ទំនងជាមួយក្រុមហ៊ុនផ្នែកដោនស្ទ្រីម និងស្នើ

ឲ្យពួកគេធ្វើការពិនិត្យដ៏ត្រឹមត្រូវផ្ទាល់ដោយខ្លួនឯង។ ក្រុមហ៊ុនផ្នែកអាប់ស្ទ្រីម គួរលើកទឹកចិត្តក្រុមហ៊ុនផ្នែកដោនស្ទ្រីម យកទិន្នន័យពីក្រុមហ៊ុនដែលកំពុងធ្វើការពិនិត្យដ៏ត្រឹមត្រូវ ឬសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់ ធ្វើការពិនិត្យដ៏ត្រឹមត្រូវ។

**ក្រុមហ៊ុនប្រតិបត្តិការផ្នែកដោនស្ទ្រីម** ត្រូវបង្កើតប្រព័ន្ធតម្លាភាពសម្រាប់ខ្សែចង្វាក់ផលិតកម្ម ដើម្បីប្រមូលទិន្នន័យ អំពីតួអង្គសំខាន់ៗនៅក្នុងខ្សែចង្វាក់ផលិតកម្ម ដើម្បីកំណត់ចំណុចរាំងស្ទះ (សូមមើលជំហានទី៤ និងឯកសារបន្ថែម) និងប្រទេស និងតំបន់ដែលពួកគេមានប្រភពមកពី។

៧.១.៤ ពង្រឹងការទំនាក់ទំនងរបស់ក្រុមហ៊ុនជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់។ គោលនយោបាយខ្សែចង្វាក់ផលិតកម្មត្រូវមានដាក់បញ្ចូលទៅក្នុងកិច្ចសន្យា និង/ឬ កិច្ចព្រមព្រៀងជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់ ដូចដែលមាននៅក្នុង ប្រការទី ២.៣.១ នៃគោលការណ៍ណែនាំរបស់ចិន ស្តីពីទំនួលខុសត្រូវក្នុងការវិនិយោគធនធានរ៉ែ។ ប្រសិនបើអាច ត្រូវជួយក្រុមហ៊ុនផ្គត់ផ្គង់ក្នុងការកសាងសមត្ថភាព ដោយគិតអំពីការធ្វើឲ្យប្រសើរឡើងនូវការអនុវត្តការពិនិត្យដ៏ត្រឹមត្រូវ។

៧.១.៥ បង្កើតយន្តការបណ្តឹងតវ៉ានៅកម្រិតក្រុមហ៊ុន ឬកម្រិតឧស្សាហកម្ម ដែលជាផ្នែកមួយនៃប្រព័ន្ធព្រមានហានិភ័យទុកជាមុន ។

## ៧.២. កំណត់ និងវាយតម្លៃហានិភ័យ នៅក្នុងខ្សែចង្វាក់ផលិតកម្ម ក្រុមហ៊ុនត្រូវអនុវត្តដូចខាងក្រោម៖

៧.២.១ **ក្រុមហ៊ុនប្រតិបត្តិការផ្នែកអាប់ស្ទ្រីម** ត្រូវប្រមូល ពិនិត្យមើល និងផ្ទៀងផ្ទាត់ខ្សែសង្វាក់នៃការគ្រប់គ្រង ឬការតាមដានព័ត៌មានឲ្យបានសមស្រប និងសហការជាមួយក្រុមហ៊ុនផ្គត់ផ្គង់ ដើម្បីកំណត់ និងបញ្ជាក់ឲ្យច្បាស់លើព័ត៌មាននៃប្រភពវត្ថុធាតុផ្សេងៗ និងសក្តានុពលនៃសញ្ញាព្រមានដែលអាចកើតមាន នៅក្នុងខ្សែចង្វាក់ផលិតកម្ម។

**ក្រុមហ៊ុនប្រតិបត្តិការផ្នែកដោនស្ទ្រីម** ត្រូវកំណត់វត្ថុធាតុផ្សេងៗដែលទាក់ទងនឹងការផលិត និងខំប្រឹងប្រែងឲ្យអស់លទ្ធភាពក្នុងការកំណត់អត្តសញ្ញាណតួអង្គសំខាន់ៗនៅក្នុងខ្សែចង្វាក់ផលិតកម្ម។

៧.២.២ ចំពោះក្រុមហ៊ុនផ្គត់ផ្គង់ បើសិនជាប្រភព ឬស្ថានភាពណាមួយនាំឲ្យមានសក្តានុពលនៃហានិភ័យ ឬសញ្ញាព្រមានណាមួយកើតមានឡើង ត្រូវអនុវត្តការពិនិត្យដ៏ត្រឹមត្រូវដែលប្រសើរ ដើម្បីកំណត់នូវហានិភ័យ ក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ។

**ក្រុមហ៊ុនប្រតិបត្តិការផ្នែកអាប់ស្ទ្រីម** ចំពោះប្រភពធនធានរ៉ែ ត្រូវធ្វើការវាយតម្លៃលើហានិភ័យ ដោយបុគ្គល ឬតាមរយៈកិច្ចសហការ ដើម្បីប្រមូលពត៌មានអំពីលក្ខខណ្ឌគុណភាពនៃផលិតកម្ម ការរៀបចំនិងពាណិជ្ជកម្ម។ សម្រាប់ប្រភពកែច្នៃ ក្រុមហ៊ុនត្រូវធ្វើការវាយតម្លៃដែលផ្អែកលើហានិភ័យ លើលទ្ធភាពដែលថា វត្ថុធាតុដើមអាចនឹងត្រូវបន្លំ តាមរយៈវិធីសាស្ត្រកែច្នៃ ដើម្បីបិទបាំង ឬលាក់ប្រភពដើមរបស់ពួកវា។

**ក្រុមហ៊ុនប្រតិបត្តិការផ្នែកដោនស្ទ្រីម** ត្រូវធ្វើការវាយតម្លៃហានិភ័យ តាមរយៈការវាយតម្លៃ ថាតើតួអង្គសំខាន់ៗនៅផ្នែកអាប់ស្ទ្រីម រួមទាំងចំណុចរាំងស្ទះ ធ្វើការពិនិត្យដ៏ត្រឹមត្រូវ ឧទាហរណ៍ ដោយពិនិត្យមើលឡើងវិញនូវព័តមានសវនកម្មដែលមានស្រាប់ គោលនយោបាយដែលអាចរកបាន និងរបាយការណ៍ជាសាធារណៈ។ ចំពោះផលិតកម្មដែលមានលក្ខណៈស្មុគស្មាញ ក្រុមហ៊ុនប្រតិបត្តិការផ្នែកដោនស្ទ្រីម ដែលពិបាកក្នុងការកំណត់អត្តសញ្ញាណតួអង្គសំខាន់ៗនៅផ្នែកអាប់ស្ទ្រីម ពីអ្នកផ្គត់ផ្គង់ដោយផ្ទាល់ របស់ពួកគេ អាចនឹងទំនាក់ទំនងជាមួយតួអង្គសំខាន់ៗនៅផ្នែកអាប់ស្ទ្រីម ជាលក្ខណៈបុគ្គល ឬតាមវិស័យ និងលើកទឹកចិត្តឲ្យមានការអនុវត្តការពិនិត្យដ៏ត្រឹមត្រូវ និងការចូលរួមនៅក្នុងការធ្វើសវនកម្ម។

៧.២.៣ ធ្វើការវាយតម្លៃហានិភ័យនៃផលប៉ះពាល់អវិជ្ជមាន ដែលមានចែងក្នុងមាតិកាចំណុចទី៥នៃគោលការណ៍ណែនាំនេះ និងបទដ្ឋាននៃគោលនយោបាយខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ ដែលមាននៅក្នុងគោលនយោបាយខ្សែចង្វាក់ផលិតកម្មគំរូ (ឧបសម្ព័ន្ធ) និងអនុសាសន៍លើការពិនិត្យដ៏ត្រឹមត្រូវ នៅក្នុងគោលការណ៍ណែនាំនេះ។

## ៧.៣. បង្កើត និងអនុវត្តវិធីសាស្ត្រ ដើម្បីឆ្លើយតបទៅនឹងហានិភ័យដែលបានរកឃើញ

៧.៣.១ រាយការណ៍នូវការរកឃើញនៃការវាយតម្លៃលើហានិភ័យនៃខ្សែចង្វាក់ផលិតកម្មទៅកាន់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនដែលត្រូវបានចាត់តាំង។

៧.៣.២ រៀបចំ និងអនុវត្តផែនការគ្រប់គ្រងហានិភ័យ។ បង្កើតយុទ្ធសាស្រ្តមួយសម្រាប់ការគ្រប់គ្រងហានិភ័យដោយ

1. បន្តការធ្វើពាណិជ្ជកម្ម តាមរយៈកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយហានិភ័យ
2. ផ្អាកការធ្វើពាណិជ្ជកម្ម បណ្តោះអាសន្ន ដោយបន្តកាត់បន្ថយហានិភ័យ
3. បញ្ឈប់ការធ្វើពាណិជ្ជកម្មជាមួយនឹងក្រុមហ៊ុនផ្គត់ផ្គង់ បន្ទាប់ពីបរាជ័យក្នុងការកាត់បន្ថយហានិភ័យ ឬ នៅពេលដែលវិធីកាត់បន្ថយហានិភ័យរបស់ក្រុមហ៊ុនទាំងនោះមិនអាចធ្វើទៅបាន ឬហានិភ័យមិនអាចទទួលយកបាន។

ដើម្បីកំណត់យុទ្ធសាស្រ្តដែលត្រឹមត្រូវ ក្រុមហ៊ុនត្រូវពិនិត្យមើលឧបសម្ព័ន្ធនិងពិចារណាលើឥទ្ធិពលរបស់ពួកគេ ហើយក្នុងករណីចាំបាច់ ត្រូវចាត់វិធានការក្នុងការពង្រីកអានុភាពជាមួយក្រុមហ៊ុនផ្គត់ផ្គង់ណា ដែលអាចបង្ការ ឬកាត់បន្ថយហានិភ័យដែលរកឃើញដោយមានប្រសិទ្ធភាពជាងគេបំផុត។ ប្រសិនបើ ក្រុមហ៊ុនបន្តកិច្ចប្រឹងប្រែងលើការកាត់បន្ថយហានិភ័យ នៅខណៈពេលជាមួយគ្នានឹងការបន្តធ្វើពាណិជ្ជកម្ម ឬផ្អាកការធ្វើពាណិជ្ជកម្មជាបណ្តោះអាសន្ន ពួកគេត្រូវធ្វើការពិភាក្សាជាមួយអ្នកផ្គត់ផ្គង់ និងអ្នកពាក់ព័ន្ធដែលរងផលប៉ះពាល់ រួមទាំងអាជ្ញាធរថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ ឬអង្គការសង្គមស៊ីវិល និងភាគីទី៣ដែលរងផលប៉ះពាល់ ទៅតាមភាពសមស្រប ហើយព្រមព្រៀងលើយុទ្ធសាស្រ្តកាត់បន្ថយហានិភ័យ នៅក្នុងផែនការគ្រប់គ្រងហានិភ័យ។

មុនពេលបញ្ឈប់ការធ្វើពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវបានលើកទឹកចិត្តខ្ពស់ ក្នុងការគិតគូរពីផលប៉ះពាល់សេដ្ឋកិច្ចសង្គមដែលអាចកើតមាន ចំពោះសហគមន៍ប្រតិបត្តិការរ៉ែ ដូចជាហានិភ័យនៃការបាត់បង់ចំណូលធ្ងន់ធ្ងរ និង/ឬសម្រាប់ទ្រទ្រង់ជីវិត នៅក្នុង ឬជិតតំបន់ប្រតិបត្តិការធនធានរ៉ែ ឬការខូចខាតសកម្មភាពសេដ្ឋកិច្ចសំខាន់ របស់សុខមាលភាពសហគមន៍ នៅក្នុង ឬជិតតំបន់ប្រតិបត្តិការធនធានរ៉ែ។

៧.៣.៣ អនុវត្តផែនការគ្រប់គ្រងហានិភ័យ ពិនិត្យមើល និងតាមដានលើប្រតិបត្តិការនៃការកាត់បន្ថយហានិភ័យ និងរាយការណ៍ទៅថ្នាក់គ្រប់គ្រងជាន់ខ្ពស់របស់ក្រុមហ៊ុនដែលត្រូវបានចាត់តាំង។

៧.៣.៤ អនុវត្តការវាយតម្លៃបន្ថែមលើហានិភ័យ និងព័ត៌មានសម្រាប់កាត់បន្ថយហានិភ័យដែលចាំបាច់ ឬបន្ទាប់ពីមានការផ្លាស់ប្តូរស្ថានភាពណាមួយ។

## ៧.៤. បន្តការធ្វើសវនកម្មឯករាជ្យដោយភាគីទី៣ នៅដំណាក់កាលដែលបានកំណត់នៅក្នុងខ្សែចង្វាក់ផលិតកម្ម

នៅដំណាក់កាលដែលបានកំណត់នៅក្នុងខ្សែចង្វាក់ផលិតកម្ម ក្រុមហ៊ុនទាំងអស់ ត្រូវធ្វើសវនកម្មឯករាជ្យលើការអនុវត្តការពិនិត្យដ៏ត្រឹមត្រូវ ដោយភាគីទី៣ ។ នៅពេលដែលក្រុមហ៊ុន ត្រូវបានរំពឹងទុក ក្នុងការកំណត់ដំណាក់កាលទាំងនោះ តាមរយៈការវាយតម្លៃហានិ-ភ័យដោយយកចិត្តទុកដាក់ ទៅលើខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ ពួកគេត្រូវគិតគូរពីចំណុចរាំងស្ទះ តាមវិស័យនិងតាមធនធានជាក់លាក់ ។

ចំពោះគោលការណ៍ណែនាំនេះ ចំណុចរាំងស្ទះ ត្រូវបានកំណត់និយមន័យ ដោយប្រើប្រាស់លក្ខខណ្ឌមួយចំនួន ដូចខាងក្រោម៖

1) បំលាស់ប្តូរសំខាន់ៗ នៅក្នុងខ្សែចង្វាក់ផលិតកម្ម
2) ដំណាក់កាលនៅក្នុងខ្សែចង្វាក់ផលិតកម្ម ដែលរួមបញ្ចូលតួអង្គមួយចំនួនដែលកាន់កាប់ឧស្សាហកម្មភាគច្រើន
3) ដំណាក់កាលនៅក្នុងខ្សែចង្វាក់ផលិតកម្ម ដែលមានកេរ្តិ៍ឈ្មោះ និងឥទ្ធិពលលើផលិតកម្ម និងពាណិជ្ជកម្មធនធានរ៉ែ
4) ចំណុចអានុភាពលើផលិតកម្ម និងពាណិជ្ជកម្មធនធានរ៉ែ

ក្នុងករណីដែលត្រូវជៀសវាងការធ្វើសវនកម្មជាន់គ្នា ចំពោះខ្សែចង្វាក់ផលិតកម្មរបស់ធនធានជាក់លាក់មួយចំនួន នៅក្នុងស្ថានភាពខ្លះ ការធ្វើសវនកម្មដោយភាគីទី៣ទៅលើពហុចំណុចរាំងស្ទះ ជាការចាំបាច់។ ក្រុមហ៊ុនទាំងនៅផ្នែកអាប់ស្ទ្រីម និងផ្នែកដោនស្ទ្រីមត្រូវរៀបចំផែនការរួម ក្នុងការបែងចែកការចំណាយលើសវនកម្មទាំងនេះ ប្រសិនបើអាច

ដោយរាប់បញ្ចូលទាំងការជួយកសាងសមត្ថភាពក្រុមហ៊ុន ដើម្បីបំពេញតាមការរំពឹងទុក និងការប្តេជ្ញាចិត្តបំពេញតាមតម្រូវការអ្នកទិញគ្រប់គ្រាន់[19] ។

សវនកម្មទាំងនេះ អាចត្រូវបានផ្ទៀងផ្ទាត់ ដោយយន្តការស្ថាប័នឯករាជ្យ ឧទាហរណ៍កម្ម-វិធីឧស្សាហកម្ម។ ចំណុចរាំងស្ទះទៅតាមធនធានជាក់លាក់ និងតម្រូវការសវនកម្មដែលពាក់ព័ន្ធ នឹងត្រូវកំណត់ និងពន្យល់បន្ថែមនៅក្នុងនីតិវិធីសវនកម្ម។

## ៧.៥. រាយការណ៍លើដំណើរការ និង លទ្ធផលនៃការគ្រប់គ្រង់ហានិភ័យនៃខ្សែចង្វាក់ផលិតកម្ម

ក្រុមហ៊ុនត្រូវរៀបចំរបាយការណ៍ជាសាធារណៈ អំពីគោលនយោបាយ និងការប្រតិបត្តិនៃការពិនិត្យដ៏ត្រឹមត្រូវនៅក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ រួមទាំងហានិភ័យដែលបានរកឃើញ និងជំហានសម្រាប់អនុវត្ត ក្នុងការកាត់បន្ថយហានិភ័យទាំងនោះ ហើយអាចធ្វើតាមរយៈការពង្រីកវិសាលភាពនៃនិរន្តរភាពរបស់ពួកគេ ទំនួលខុសត្រូវរបស់សារជីវកម្មចំពោះសង្គម ឬរបាយការណ៍ប្រចាំឆ្នាំ អំពីពត៌មានបន្ថែមលើការពិនិត្យដ៏ត្រឹមត្រូវក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ។

---

[19] យោងតាមបទដ្ឋាន ISO 26000 ចំណុច 6.6.6. ស្តីពីប្រតិបត្តិការដោយស្មើភាព លេខ៤ ជម្រុញទំនួលខុសត្រូវសង្គមនៅក្នុងខ្សែសង្វាក់តម្លៃ

# ៨. សវនកម្ម លិខិតបញ្ជាក់ និងការត្រួតពិនិត្យ

គោលបំណងចម្បងនៃការធ្វើសវនកម្ម និងលិខិតបញ្ជាក់ដោយភាគីទីបី គឺជាការបញ្ជាក់ពីទំនុកចិត្តទៅឲ្យអ្នកពាក់ព័ន្ធខាងក្រៅ ថាក្រុមហ៊ុនមួយ មានគោលនយោបាយ និងការប្រតិបត្តិដែលសមស្រប និងមានប្រសិទ្ធភាព ដើម្បីទប់ស្កាត់ កំណត់ និងកាត់បន្ថយហានិភ័យក្នុងខ្សែចង្វាក់ផលិតកម្មធនធានរ៉ែ និងប្រភពធនធានរ៉ែ ដោយមានទំនួលខុសត្រូវ និងការយកចិត្តទុកដាក់ខ្ពស់លើជម្លោះ។

ក្រុមហ៊ុនមានទំនួលខុសត្រូវរៀងៗខ្លួន ក្នុងការអនុវត្តការពិនិត្យដ៏ត្រឹមត្រូវក្នុងខ្សែចង្វាក់ផលិតកម្មរបស់ពួកគេ ក្នុងការធ្វើសវនកម្មដោយភាគីទីបីដែលចាំបាច់ណាមួយ ដូចដែលបានលើកឡើង ហើយនិងក្នុងការផ្សព្វផ្សាយគោលនយោបាយនៃការពិនិត្យដ៏ត្រឹមត្រូវ និងការប្រតិបត្តិរបស់ពួកគេ ដោយយោងទៅតាមគោលការណ៍ណែនាំនេះ។

គោលការណ៍ណែនាំនេះ នឹងអាចកំណត់នូវប្រព័ន្ធមួយដែលអាចឲ្យក្រុមហ៊ុនទទួលលិខិតបញ្ជាក់។ លិខិតបញ្ជាក់ ជាការធានាបន្ថែមមួយទៀត សម្រាប់ក្រុមហ៊ុន[20] ដែលនៅក្នុងនោះ គោលនយោបាយនៃការពិនិត្យដ៏ត្រឹមត្រូវ និងការប្រតិបត្តិរបស់ក្រុមហ៊ុន ព្រមទាំងការធ្វើសវនកម្មដោយភាគីទីបី នឹងត្រូវវាយតម្លៃផ្ទៀងផ្ទាត់ដោយអង្គភាពត្រួតពិនិត្យឯករាជ្យមួយ ។

ប្រព័ន្ធសវនកម្ម និងលិខិតបញ្ជាក់ នឹងពន្យល់លម្អិតនៅក្នុងឯកសារដាច់ដោយឡែកផ្សេង។

បន្ថែមពីលើនេះទៀត អ្នកពាក់ព័ន្ធអាចដាក់ពាក្យបណ្តឹង យោងទៅតាមគោលការណ៍ណែនាំនេះ។ យន្តការដោះស្រាយបណ្តឹង នឹងត្រូវរៀបរាប់ដាច់ដោយឡែក នៅក្នុងឧបសម្ព័ន្ធ។

[20] យោងតាមបទដ្ឋានធានារបស់ ISEAL Assurance Code ការធានាត្រូវបានឲ្យនិយមន័យថា "ភស្តុតាងដែលអាចបញ្ជាក់ពីការបំពេញបាននូវតម្រូវការដាក់លាក់ទាំងឡាយណាសម្រាប់ផលិតកម្ម ដំណើរការ ប្រព័ន្ធ បុគ្គល ឬស្ថាប័ន (យកពី ISO 17000)"

# ឧបសម្ព័ន្ធ ៖ គោលនយោបាយខ្សែចង្វាក់ផលិតកម្មគំរូ

## សេចក្តីផ្តើម

គោលការណ៍ណែនាំរបស់ចិន ស្តីអំពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ទាមទារឲ្យក្រុមហ៊ុនដែលជាសមាជិក "កំណត់ក្រមសីលធម៌មួយដែលតម្រូវឲ្យអ្នកផ្គត់ផ្គង់គោរពតាមតម្រូវការដែលមានពាក់ព័ន្ធនៅក្នុងគោលការណ៍ណែនាំរបស់ចិន ស្តីអំពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ហើយលើកទឹកចិត្តឲ្យអ្នកផ្គត់ផ្គង់ទាំងនោះ ចុះហត្ថលេខាលើឯកសារនោះ" យោងតាមប្រការ ២.៣.១។

គោលនយោបាយខ្សែចង្វាក់ផលិតកម្មគំរូខាងក្រោមនេះ អាចជាឯកសារគំរូសំរាប់បញ្ហាជាអាទិភាពផ្សេងៗ ដែលមាននៅក្នុងក្រមសីលធម៌របស់អ្នកផ្គត់ផ្គង់។ ក្រុមហ៊ុនទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យដាក់បញ្ចូលតម្រូវការទាំងអស់ ដែលមាននៅក្នុងគោលការណ៍ណែនាំរបស់ចិន ស្តីអំពីទំនួលខុសត្រូវក្នុងការវិនិយោគរ៉ែ ទៅក្នុងក្រមសីលធម៌នៃខ្សែចង្វាក់ផលិតកម្មរបស់ខ្លួន ដោយយោងទៅតាមប្រការ ២.៣.១ ។

## គោលនយោបាយខ្សែចង្វាក់ផលិកម្មគំរូ

ដោយទទួលស្គាល់ថាហានិភ័យនៃផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរ អាចកើតមានពីសកម្មភាពប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ និងការនាំចេញធនធានរ៉ែពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ ហើយដោយយល់ថាយើងមានទំនួលខុសត្រូវក្នុងការគោរពសិទ្ធិមនុស្ស និងមិនចូលរួមក្នុងការនាំឲ្យមានជម្លោះ និងនាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើបរិស្ថាននិងសង្គម យើងប្តេជ្ញាអនុម័ត ផ្សព្វផ្សាយយ៉ាងទូលំទូលាយ និងដាក់បញ្ចូលនៅក្នុងកិច្ចសន្យា និង/ឬកិច្ចព្រមព្រៀងផ្សេងៗជាមួយអ្នកផ្គត់ផ្គង់ អំពីគោលនយោបាយ ស្តីអំពីការទទួលប្រភពធនធានរ៉ែប្រកបដោយទំនួលខុសត្រូវដោយយោងទៅតាមគោលការណ៍ណែនាំនេះ អំពីប្រតិបត្តិការទទួលទិញពីតំបន់ដែលងាយមានជម្លោះ និងការយល់ដឹងពីហានិភ័យរបស់អ្នកផ្គត់ផ្គង់ ចាប់តាំងពីប្រតិបត្តិការធនធានរ៉ែ រហូតដល់អ្នកប្រើប្រាស់ចុងក្រោយ។ យើងនឹងមិនធ្វើសកម្មភាពណា ដែលចូលរួមចំណែកហិរញ្ញប្បទានដល់ជម្លោះ ហើយយើងក៏ប្តេជ្ញាគោរពទៅតាមដំណោះស្រាយដាក់ទណ្ឌកម្មរបស់អង្គការសហប្រជាជាតិ ឬច្បាប់ជាតិណាទាក់ទងទៅនឹងដំណោះស្រាយបែបនេះ ប្រសិនបើមាន ។

## ១. ការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ

យើងនឹងមិនលើកលែង ឬទទួលយកផលចំណេញពី ចូលរួមចំណែកជាមួយ ឬជួយ ឬសម្របសម្រួល ដើងសារឲ្យភាគីណាមួយនូវៈ

- គ្រប់ទម្រង់ទាំងអស់នៃការធ្វើទារុណ្ណកម្ម អំពើព្រៃផ្សៃ អមនុស្សធម៌ និងការបន្ទាបបន្ថោក
- គ្រប់ទម្រង់ទាំងអស់នៃការប្រើកំលាំងពលកម្មដោយការបង្ខំ ដែលមានន័យថា ការងារ ឬ សេវាកម្មទាំងឡាយណាដែលបុគ្គលណាមួយបំពេញ ក្រោមការគំរាមកំហែងនៃការដាក់ពិន័យ ហើយដែលបុគ្គលនោះមិនបានធ្វើដោយការស្ម័គ្រចិត្ត
- ទម្រង់អាក្រក់បំផុតនៃការប្រើកំលាំងពលកម្មកុមារ
- ការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរផ្សេងៗទៀត ដូចជាអំពើហិង្សាផ្លូវភេទ
- ឧក្រិដ្ឋកម្មសង្គ្រាម ឬការរំលោភធ្ងន់ធ្ងរផ្សេងៗ លើច្បាប់មនុស្សធម៌អន្តរជាតិ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ឬអំពើប្រល័យពូជសាសន៍ ។

### ការកាត់បន្ថយហានិភ័យ

យើងនឹងធ្វើការផ្អាក ឬបញ្ឈប់ប្រតិបត្តិការភ្លាមៗជាមួយនឹងអ្នកផ្គត់ផ្គង់ផ្នែកអាប់ស្ទ្រីម នៅពេលណាដែលយើងរកឃើញហានិភ័យច្បាស់លាស់ណាមួយ ដែលពួកគេទទួលទិញពីប្រភព ឬមានជាប់ពាក់ព័ន្ធទៅនឹងភាគីណាមួយដែលបានរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរ ។

## ២. ការជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោលដល់ក្រុមប្រដាប់អាវុធមិនមែនរដ្ឋ និងកង កំលាំងសន្តិសុខឯកជន ឬសាធារណៈ

យើងនឹងមិនលើកលែងចំពោះការជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោល ដល់ក្រុមប្រដាប់អាវុធមិនមែនរដ្ឋ ចំពោះសកម្មភាពប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ និងការនាំចេញធនធានរ៉ែនោះទេ ។ "ការជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោល" ដល់ក្រុមប្រដាប់អាវុធមិនមែនរដ្ឋ ចំពោះសកម្មភាពប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ និងការនាំចេញធនធានរ៉ែ រួមមានជាអាទិ៍ដូចជា ការបញ្ជាទិញធនធានពី ការចំណាយទៅឲ្យ ឬការផ្តល់ជំនួយភស្តុភារ ឬឧបករណ៍ផ្សេងៗទៅឲ្យក្រុមប្រដាប់អាវុធខុសច្បាប់ ឬដៃគូរបស់ពួកគេ ដែលៈ

- គ្រប់គ្រងតំបន់ប្រតិបត្តិការរ៉ែដោយខុសច្បាប់ ឬគ្រប់គ្រងផ្លូវដឹកជញ្ជូន ឬចំនុចដែលធនធានរ៉ែត្រូវធ្វើពាណិជ្ជកម្ម និងជាតួអង្គផ្នែកអាប់ស្ទ្រីមនៅក្នុងខ្សែចង្វាក់ផលិតកម្ម និង/ឬ
- យកពន្ធ ឬគំរាមយកប្រាក់ ឬធនធានរ៉ែ ដោយខុសច្បាប់នៅកន្លែងទីតាំងយករ៉ែ នៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ និង/ឬ
- យកពន្ធ ឬគំរាមយកប្រាក់ពីឈ្មួញកណ្ដាល ក្រុមហ៊ុននាំចេញ ឬពាណិជ្ជករអន្តរជាតិ ដោយខុសច្បាប់

យើងនឹងមិនមានការជួយជ្រោមជ្រែងដោយផ្ទាល់ ឬ ដោយប្រយោល ដល់កងកំលាំងសន្តិសុខឯកជន ឬសាធារណៈ ដែលគ្រប់គ្រងតំបន់ប្រតិបត្តិការរ៉ែដោយខុសច្បាប់ ឬគ្រប់គ្រងផ្លូវដឹកជញ្ជូន និងជាតួអង្គផ្នែកអាប់ស្ទ្រីមនៅក្នុងខ្សែចង្វាក់ផលិតកម្ម យកពន្ធ ឬគំរាមយកប្រាក់ ឬធនធានរ៉ែ ដោយខុសច្បាប់នៅកន្លែងទីតាំងយករ៉ែ នៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ ឬ យកពន្ធ ឬគំរាមយកប្រាក់ពីឈ្មួញកណ្ដាល ក្រុមហ៊ុននាំចេញ ឬពាណិជ្ជករអន្តរជាតិ ដោយខុសច្បាប់។

យើងទទួលស្គាល់ថាតួនាទីរបស់កងកំលាំងសន្តិសុខឯកជន ឬសាធារណៈនៅទីតាំងយករ៉ែ និង/ឬនៅជុំវិញតំបន់ទាំងនោះ និង/ឬ នៅតាមផ្លូវដឹកជញ្ជូន ត្រូវតែធ្វើឡើងដើម្បីរក្សានិតិរដ្ឋ ដែលរួមបញ្ចូលការការពារសិទ្ធិមនុស្ស ផ្ដល់សន្តិសុខដល់បុគ្គលិកកម្មករ ឧបករណ៍ និងគ្រឿងបរិក្ខារផ្សេងៗ ព្រមទាំងការពារតំបន់ប្រតិបត្តិការរ៉ែ ឬផ្លូវដឹកជញ្ជូនពីការរំខានដល់ការធ្វើពាណិជ្ជកម្ម និងប្រតិបត្តិការរ៉ែដែលស្របច្បាប់ ។

នៅពេលដែលយើងចុះកិច្ចសន្យា ឬទទួលទិញពី ឬមានជាប់ពាក់ព័ន្ធជាមួយ ក្រុមហ៊ុនឬទំនាក់ទំនងធុរកិច្ចណាមួយ នៅក្នុងខ្សែចង្វាក់ផលិតកម្ម ដែលចុះកិច្ចសន្យាជាមួយកងកំលាំងសន្តិសុខឯកជន ឬសាធារណៈណាមួយ យើងនឹងប្ដេជ្ញា ឬនឹងតម្រូវឲ្យកងកំលាំងទាំងនោះ ប្រតិបត្តិដោយគោរពទៅតាមបទដ្ឋាន និងឯកសារណែនាំដែលទទួលដោយស្គាល់ជាអន្តរជាតិ ស្ដីអំពីកងកំលាំងសន្តិសុខឯកជនឬសាធារណៈ។ ជាពិសេស យើងនឹងគាំទ្រ ឬមានការប្រើប្រាស់គោលនយោបាយផ្សេងៗ ក្នុងការត្រួតពិនិត្យមើល ដើម្បីធានាឲ្យប្រាកដថាយើងនឹងមិនមានការប្រើប្រាស់សេវាកម្មរបស់បុគ្គល ឬអង្គភាពនៃកងកំលាំងសន្តិសុខណាដែលធ្លាប់មានប្រវត្តិ រំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនោះទេ។

យើងនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ឬចាត់វិធានការផ្សេងៗ ដើម្បីសហការជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល ក្នុងការចូលរួមចំណែករកដំណោះស្រាយទាំងឡាយណា ដើម្បីឲ្យមានតម្លាភាព ភាពសមាមាត្រ និងគណនេយ្យភាពក្នុងការចំណាយទៅលើកងកំលាំងសន្តិសុខសំរាប់សេវាកម្មសន្តិសុខ ។

យើងនឹងគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ឬចាត់វិធានការផ្សេងៗ ដើម្បីសហការជាមួយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ និងអង្គការសង្គមស៊ីវិល ក្នុងការទប់ស្កាត់ ឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ដោយសារវត្តមានរបស់កងកំលាំងសន្តិសុខទាំងឯកជន និងសាធារណៈនៅទីតាំងប្រតិបត្តិការរ៉ែ ទៅលើក្រុមងាយរងគ្រោះ ជាពិសេសក្រុមសិប្បកម្មជីកយករ៉ែ ដែលធនធានរ៉ែនៅក្នុងខ្សែចង្វាក់ផលិតកម្ម ត្រូវបានជីកយកដោយអ្នកសិប្បកម្មជីកយករ៉ែឬអាជីវកម្មខ្នាតតូច។

## ការកាត់បន្ថយហានិភ័យ

យើងនឹងធ្វើការផ្អាក ឬ បញ្ឈប់ប្រតិបត្តិការភ្លាមៗជាមួយនឹងអ្នកផ្គត់ផ្គង់ផ្នែកអាប់ស្ទ្រីម នៅពេលណាដែលយើងរកឃើញហានិភ័យច្បាស់លាស់ណាមួយ ដែលពួកគេទទួលទិញប្រភព ឬមានជាប់ពាក់ព័ន្ធទៅនឹងភាគីណាមួយ ដែលជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោលដល់ក្រុមប្រដាប់អាវុធមិនមែនរដ្ឋ ។

ដោយផ្អែកទៅលើតួនាទីរបស់ក្រុមហ៊ុននីមួយៗនៅក្នុងខ្សែចង្វាក់ផលិតកម្ម យើងនឹងបង្កើត ប្រើប្រាស់ និងអនុវត្តភ្លាមៗ នូវផែនការគ្រប់គ្រងហានិភ័យ ចំពោះហានិភ័យដែលអាចកើតមាន ជាមួយនឹងអ្នកផ្គត់ផ្គង់ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យនៃការជួយជ្រោមជ្រែងដោយផ្ទាល់ ឬដោយប្រយោល ដល់កងកំលាំងសន្តិសុខទាំងឡាយណា ដែលគ្រប់គ្រងតំបន់ប្រតិបត្តិការរ៉ែដោយខុសច្បាប់ ឬគ្រប់គ្រងផ្លូវដឹកជញ្ជូន និងជាតួអង្គផ្នែកអាប់ស្ទ្រីមនៅក្នុងខ្សែចង្វាក់ផលិតកម្មយកពន្ធ ឬគំរាមយកប្រាក់ ឬធនធានរ៉ែ ដោយខុសច្បាប់នៅកន្លែងទីតាំងយករ៉ែ នៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ ឬយកពន្ធ ឬគំរាមយកប្រាក់ពីឈ្មួញកណ្តាល ក្រុម-ហ៊ុននាំចេញ ឬពាណិជ្ជករអន្តរជាតិ ដោយខុសច្បាប់ ។ ក្នុងករណីទាំងនេះ យើងនឹងផ្អាក ឬបញ្ឈប់ប្រតិបត្តិការជាមួយអ្នកផ្គត់ផ្គង់ទាំងនោះ បន្ទាប់ពីការព្យាយាមកាត់បន្ថយហានិភ័យ មិនបានទទួលជោគជ័យក្នុងរយៈពេល៦ខែ បន្ទាប់ពីបានអនុវត្តផែនការគ្រប់គ្រងហានិភ័យ ។

## ៣. អំពើពុករលួយ ការលាងលុយកខ្វក់ និងការចំណាយជាមួយរដ្ឋាភិបាល

យើងនឹងមិនធ្វើការស្នើ សន្យា ផ្តល់ឲ្យ ឬទាមទារសំណូកណាមួយ ហើយនឹងបដិសេធសំណូកទាំងអស់ដើម្បីបិទបាំង ឬក្លែងបន្លំ នូវប្រភពដើមរបស់ធនធានរ៉ែ បន្ទំពន្ធ ថ្លៃឈ្នួលនិងកម្រៃសួយសារ ដែលត្រូវបង់ជូនរដ្ឋាភិបាល សម្រាប់សកម្មភាពប្រតិបត្តិការ ពាណិជ្ជកម្ម ការដឹកជញ្ជូន និងនាំចេញធនធានរ៉ែ ។

យើងនឹងហាមឃាត់ការផ្តល់សំណូក នៅក្នុងសកម្មភាព និងប្រតិបត្តិការធុរកិច្ចទាំងអស់ ដែលរួមទាំងសកម្មភាពរបស់ភ្នាក់ងារ និងភាគីទីបីផ្សេងៗ ព្រមទាំងនឹងដាក់លក្ខខន្តិកៈ និងនិតិវិធីអនុម័ត អំពីការផ្តល់ជូន ឬទទួលយកអំណោយ ប្រឹងប្រែងឲ្យអស់លទ្ធភាពដើម្បីលើកកម្ពស់ប្រតិបត្តិការធុរកិច្ចប្រកបដោយទំនួលខុសត្រូវ ជាមួយនឹងដៃគូធុរកិច្ចទាំងអស់ ។

យើងនឹងគាំទ្រកិច្ចខិតខំប្រឹងប្រែង ឬចាត់វិធានការផ្សេងៗ ដើម្បីចូលរួមចំណែកដោយមានប្រសិទ្ធិភាពក្នុងការលុបបំបាត់ការលាងលុយ នៅពេលដែលយើងរកឃើញថាមានហានិភ័យជាក់លាក់ណាមួយនៃការលាងលុយដែលបានមកពី ឬមានការពាក់ព័ន្ធ នឹងប្រតិបត្តិការរ៉ែ ការធ្វើពាណិជ្ជកម្ម ការចម្រាញ់ ការដឹកជញ្ជូន ឬការនាំចេញធនធានរ៉ែ ដែលមានប្រភពពីការបង់ពន្ធខុសច្បាប់ ឬការប្លន់យកធនធានរ៉ែ ក្នុងគ្រប់ចំនុចឆ្លងកាត់តំបន់ប្រតិបត្តិការធនធានរ៉ែ និងនៅតាមផ្លូវដឹកជញ្ជូន ឬនៅកន្លែងដែលធនធានរ៉ែត្រូវបានធ្វើការជួញដូរ ដោយអ្នកផ្គត់ផ្គង់នៅផ្នែកអាប់ស្ទ្រីម។

យើងប្តេជ្ញាចាត់វិធានការដ៏មានប្រសិទ្ធិភាពក្នុង ការទប់ស្កាត់ការចូលរួមក្នុងការលាងលុយ និងការផ្តល់ហិរញ្ញប្បទានដល់សកម្មភាពភេរវកម្ម ។ ឧទាហរណ៍ យើងនឹងបង្កើត និងចេញផ្សាយនូវអត្តសញ្ញាណ និងភាពជាម្ចាស់កម្មសិទ្ធិ របស់អ្នកផ្គត់ផ្គង់និងអតិថិជន តាមដានប្រតិបត្តិការទាំងឡាយ ដែលមានសកម្មភាពមិនប្រក្រតី ឬដែលគួរឲ្យសង្ស័យ ហើយយើងនឹងរក្សាទុកនូវកំណត់ត្រាអំពីប្រតិបត្តិការសាច់ប្រាក់ទាំងអស់ដែលបានកើតឡើង លើសពីការកំណត់ខាងផ្នែកហិរញ្ញវត្ថុដែលមានចែងនៅក្នុងច្បាប់ដែលពាក់ព័ន្ធ ។

យើងនឹងធានាថា រាល់ការបង់ពន្ធ ថ្លៃឈ្នួលនិងកម្រៃសួយសារផ្សេងៗ ដែលពាក់ព័ន្ធនឹងប្រតិបត្តិការ ការធ្វើពាណិជ្ជកម្ម និងការនាំចេញធនធានរ៉ែ ពីតំបន់ដែលរងប៉ះពាល់ដោយជម្លោះ និងមានហានិភ័យខ្ពស់ ដែលត្រូវបានបង់ជូនរដ្ឋាភិបាល ត្រូវគោរពទៅតាមតួនាទីរបស់ក្រុមហ៊ុននៅក្នុងខ្សែចង្វាក់ផលិតកម្ម ហើយយើងប្តេជ្ញានឹងបង្ហាញរាល់ការចំណាយទាំងនោះ ដោយគោរពទៅតាមបទដ្ឋានអន្តរជាតិ។

## ការកាត់បន្ថយហានិភ័យ

ដោយផ្អែកទៅលើតួនាទីរបស់ក្រុមហ៊ុននីមួយៗនៅក្នុងខ្សែចង្វាក់ផលិតកម្ម យើងប្តេជ្ញាថានឹងសហការជាមួយអ្នកផ្គត់ផ្គង់ រដ្ឋាភិបាលថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការអន្តរជាតិ អង្គការសង្គមស៊ីវិល និងភាគីទីបីដែលរងផលប៉ះពាល់ ទៅតាមភាពសមស្រប ដើម្បីពង្រឹង និងតាមដានប្រតិបត្តិការ ដោយផ្តោតលើការទប់ស្កាត់ និងកាត់បន្ថយហានិភ័យនៃផលប៉ះពាល់អវិជ្ជមាន តាមរយៈការអនុវត្តជំហានដែលអាចវាស់វែង ទៅតាមពេលវេលាសមស្រប ។ យើងនឹងផ្អាក ឬបញ្ឈប់ប្រតិបត្តិការជាមួយអ្នកផ្គត់ផ្គង់ផ្នែកអាប់ស្ទ្រីមណាដែលការព្យាយាមកាត់បន្ថយហានិភ័យរបស់ពួកគេមិនបានទទួលជោគជ័យ ។

## ៤. សិទ្ធិដីធ្លី ការបញ្ចេញជាតិពុល និងក្រុមសិប្បកម្មអ្នកជីកយករ៉ែ

យើងនឹងមិនចូលរួមពាក់ព័ន្ធជាមួយ ឬលើកលែងចំពោះប្រតិបត្តិការធនធានរ៉ែ ឬការទទួលបានផលប្រយោជន៍ពី ដីតំបន់ដែលមិនទទួលបានការព្រមព្រៀងជាមុន ដោយសេរី និងមានការផ្តល់ព័ត៌មានគ្រប់គ្រាន់ ពីសហគមន៍មូលដ្ឋាន និងជនជាតិភាគតិច រួមមានទាំងអ្នកដែលកាន់កាប់កម្មសិទ្ធ ការជួលសម្បទាន ឬអាជ្ញាប័ណ្ណស្របច្បាប់។ យើងនឹងមិនចូលរួមជាប់ពាក់ព័ន្ធនឹង ឬលើកលែងចំពោះប្រតិបត្តិការ ឬការទទួលបានផលប្រយោជន៍ពីការធ្វើប្រតិបត្តិការធនធានរ៉ែ ដែលវប្បធម៌និងបេតិកភ័ណ្ឌរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច មិនទទួលបានការគោរព និងការការពារ ឬកន្លែងដែលប្រពៃណីវប្បធម៌របស់សហគមន៍មូលដ្ឋាន មានការរងប៉ះទង្គិច។

យើងនឹងមិនចូលរួមពាក់ព័ន្ធជាមួយ ឬ លើកលែងចំពោះប្រតិបត្តិការ ឬការទទួលបានផលប្រយោជន៍នៅពេលដែលដីតំបន់មានកម្មសិទ្ធស្របច្បាប់ ការជួល សម្បទាន ឬ អាជ្ញាប័ណ្ណ ទទួលបានដោយខុសច្បាប់ ឬរំលោភច្បាប់ជាតិ។ យើងនឹងធានាឲ្យប្រាកដថា យើងនឹងចៀសវាងឲ្យបាននូវផលប៉ះពាល់អវិជ្ជមាន និងការរំលោភច្បាប់និងបទប្បញ្ញត្តិជាតិធ្ងន់ធ្ងរ ពាក់ព័ន្ធនឹងលក្ខខណ្ឌសមស្របនៃបរិយាកាសដី ខ្យល់ និងទឹក រួមទាំងការផលិត ពាណិជ្ជកម្ម និងការប្រើប្រាស់ សារធាតុគីមីពុលនិងសារធាតុគ្រោះថ្នាក់ ដែលត្រូវបានហាមឃាត់ជាអន្តរជាតិ ដោយសារតែកម្រិតជាតិពុលខ្ពស់របស់សារធាតុទាំងនោះមកលើសារពាង្គកាយមានជីវិត បរិស្ថាន ឬផលប៉ះពាល់អាក្រក់ដែលអាចកើតមានឡើងលើប្រព័ន្ធអេកូឡូស៊ី និង/ឬ ការបញ្ចេញសារធាតុអាសេនិច និងការបំភាយសារធាតុបារត។

យើងប្តេជ្ញាថានឹងធ្វើការវាយតម្លៃជាប្រចាំ និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើទឹក ដី និងខ្យល់ ដោយសារប្រតិបត្តិការរ៉ែ ដោយគិតពិចារណាអំពីលក្ខខណ្ឌសមស្របរបស់ទឹក ដី និងខ្យល់ ហើយប្រើ

ប្រាស់លទ្ធភាពបច្ចេកទេស និងថវិកា ដើម្បីអនុវត្តគោលការណ៍ទប់ស្កាត់ការបំពុលបរិស្ថាន និងបច្ចេកទេសដែលសមស្របជាងគេបំផុត ដើម្បីទបស្កាត់ កាត់បន្ថយ និងគ្រប់គ្រងការបំពុល តាមដានការបំភាយ និងការបញ្ចេញចោលសារជាតុពុលទាំងឡាយ ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធរបស់ប្រទេសសាមី៉ យើងនឹងតាមដាន និងដោះស្រាយបញ្ហាបំពុលបរិស្ថាន ឲ្យទាន់ពេលវេលា ព្រមទាំងធ្វើកំណត់ត្រាឲ្យបានច្បាស់លាស់ និងបង្ហាញលទ្ធផលជាសាធារណៈ ហើយថែមទាំងប្រើប្រាស់យុទ្ធសាស្ត្រកាត់បន្ថយ និងគ្រប់គ្រងការបំភាយ ។

យើងយល់ព្រមក្នុងជានាឲ្យប្រាកដ និងធ្វើឲ្យលើសពីតម្រូវការច្បាប់ពាក់ព័ន្ធនឹងសារជាតុគីមីពុលចៀសវាងការផលិត ការធ្វើពាណិជ្ជកម្ម និងការប្រើប្រាស់សារជាតុគីមីពុលនិងសារជាតុគ្រោះថ្នាក់ដទៃទៀត ដែលត្រូវបានហាមឃាត់ជាអន្តរជាតិ ដោយសារតែកម្រិតជាតិពុលខ្ពស់របស់សារជាតុទាំងនោះមកលើសារពាង្គកាយមានជីវិត បរិស្ថាន ឬផលប៉ះពាល់អាក្រក់ ដែលអាចកើតមានឡើងលើប្រព័ន្ធអេកូឡូស៊ី និង/ឬ ការបញ្ចេញសារជាតុអាសេនិច និងការបំភាយសារជាតុបារត ព្រមទាំងគ្រប់គ្រងសារជាតុស្យានីត (cyanide)ឲ្យស្របតាមបទដ្ឋានអន្តរជាតិដែលខ្ពស់បំផុត ហើយនឹងជានាឲ្យប្រាកដថាកាកសំណល់គ្រោះថ្នាក់ទាំងឡាយ ត្រូវបានគ្រប់គ្រង រក្សាទុក ដឹកជញ្ជូន ចម្រោះ និងបោះចោលដោយគោរពទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលមាន ដោយបញ្ចៀសនូវការលេចធ្លាយ កំពប់ ឬការសាយភាយដទៃទៀតទៅក្នុងបរិស្ថាន។

យើងនឹងហាមឃាត់ប្រតិបត្តិការធនធានរ៉ែ ពីតំបន់បេតិកភណ្ឌពិភពលោក ឬតំបន់ការពារស្របច្បាប់ដែលបណ្តាលឲ្យមាន ការគំរាមកំហែងដល់គុណតម្លៃសំខាន់ជាសកល ដែលត្រូវបានការពារនៅក្នុងតំបន់ទាំងនោះ។

យើងនឹងផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើហានិភ័យនៃការប្រើប្រាស់កម្លាំងពលកម្មដោយការបង្ខំ កម្លាំងពលកម្មកុមារ លក្ខខណ្ឌការងារដែលមិនមានសុវត្ថិភាព ការប្រើប្រាស់សារជាតុគ្រោះថ្នាក់ដោយមិនមានការគ្រប់គ្រងត្រឹមត្រូវ និងផលប៉ះពាល់បរិស្ថានចំបងៗផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងការទទួលទិញពីក្រុមសិប្បកម្មនិងអាជីវកម្មរ៉ែខ្នាតតូច ហើយយើងនឹងធ្វើការជាមួយគ្នានិងបង្កើតទំនាក់ទំនងដ៏មានប្រសិទ្ធិភាព ជាមួយក្រុមសិប្បកម្មនិងអាជីវកម្មរ៉ែខ្នាតតូច នៅក្នុងតំបន់ប្រតិបត្តិការរ៉ែ។

## ការកាត់បន្ថយហានិភ័យ

ដោយផ្អែកទៅលើតួនាទីរបស់ក្រុមហ៊ុននីមួយៗនៅក្នុងខ្សែចង្វាក់ផលិតកម្ម យើងនឹងបង្កើត ប្រើប្រាស់ និងអនុវត្តភ្លាមៗ នូវផែនការគ្រប់គ្រងហានិភ័យ ចំពោះហានិភ័យដែលអាចកើតមាន ជាមួយនឹងអ្នកផ្គត់ផ្គង់ និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីទប់ស្កាត់ ឬកាត់បន្ថយហានិភ័យនៃការរំលោភបំពានសិទ្ធិដីធ្លីដែលបណ្តាលឲ្យមានផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន ឬហានិភ័យជាក់លាក់ផ្សេងៗទៀតដែលទាក់ទងនឹងក្រុមសិប្បកម្មនិងអាជីវកម្មរ៉ែខ្នាតតូច ។

## សមាគមពាណិជ្ជកម្មចិននាំចេញនាំចូល
## លោហៈ រ៉ែ និងសារធាតុគីមី (CCCMC)

អាសយដ្ឋាន៖ ជាន់ទី ១៧ អគារ Prime Tower លេខ ២២ ផ្លូវ Chaowai
សង្កាត់ Chaoyang ទីក្រុងប៉េកាំង ប្រទេសចិន លេខកូដ 100020
ទូរស័ព្ទ៖ 86-010-85692865
ទូរសារ៖ 86-010-65883592
គេហទំព័រ៖ www.cccmc.org.cn
អ៊ីមែល៖ rbc@cccmc.org.cn